ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥
រចាយការណ៍ចុងក្រោយ



វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ

សហការជាមួយ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ជំនួយបច្ចេកទេសពី អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា

Food and Agriculture Organization of the United Nations



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍អត្ថតកសិកម្មកម្ពុជាឆ្នាំ២០២៥













Food and Agriculture Organization of the United Nations

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

សហការជាមួយ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

មាតិកា

បុព្វកថា i
អារម្ភកថា iii
អក្សរកាត់ iv
រចនាសម្ព័ន្ធរបាយការណ៍ v
ផ្នែកទី១៖ វិធីសាស្ត្រអង្កេត ១
របាយការណ៍សង្ខេប ១
ទំហំ វិសាលភាព និងការជ្រើសរើសសំណាកគំរូ ៩
ផ្នែកទី២៖ ផ្ទៃដីកសិកម្ម និងផលិតកម្មដំណាំ ១៩
ផ្ទៃដីកសិកម្ម ១៩
ផលិកម្មដំណាំ ២២
ដំណាំរយៈពេលខ្លី ២៣
ដំណាំរយៈពេលវែង ២៨
ផ្នែកទី៣៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ៣៧
បសុសត្វប្រភេទធំ ៣៨
បសុសត្វប្រភេទតូច ៤៤
បសុបក្សី ៤៧
ផ្នែកទី៤៖ វារីវប្បកម្ម និងការនេសាទ ៥៦
វារីវប្បកម្ម ៥៦
ការនេសាទ ៥៨
ផ្នែកទី៥៖ កម្លាំងពលកម្ម និងសកម្មភាពសេដ្ឋកិច្ច ៦២
កម្លាំងពលកម្ម ៦២
សេដ្ឋកិច្ច ៦៨
ប្រាក់កម្ចី ៧២
គ្រោះហានិភ័យ ៧៤

បញ្ជីរូបភាព

រូបទី២.១: ផ្ទៃដីកសិកម្មសរុប តាមប្រភេទទំហំ និងតំបន់ ឆ្នាំ២០២៥ ២០
រូបទី២.២: ផ្ទៃដីកសិកម្ម តាមចំណាត់ថ្នាក់ នៅប្រទេសកម្ពុជា ឆ្នាំ២០២៥ ២០
រូបទី២.៣: ប្រភពនៃការទទួលបានក្បាលដីតាមគ្រួសារកសិកម្មនៅកម្ពុជា ឆ្នាំ២០២៥ ២១
រូបទី២.៤ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ពីប្រភេទដំណាំ១០មុខសំខាន់ៗនៅកម្ពុជា ឆ្នាំ២០២៥ ២៣
រូបទី២.៥ ផ្ទៃដីដំណាំស្រូវធម្មតា បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៥ ២៤
រូបទី២.៦ ផ្ទៃដីដំណាំស្រូវក្រអូប បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៥ ២៥
រូបទី២.៧: ចំនួនគ្រួសារដែលរាយការណ៍ដាំដំឡូងមី តាមតំបន់ ឆ្នាំ២០២៥ ២៦
រូបទី២.៨ ចំនួនគ្រួសារដែលរាយការណ៍ដាំអំពៅ តាមតំបន់ ឆ្នាំ២០២៥ ២៧
រូបទី២.៩ ចំនួនគ្រួសារកសិកម្ម ដាំបន្លែមានផ្លែ តាមប្រភេទដំណាំ នៅកម្ពុជា ឆ្នាំ២០២៥ ២៨
រូបទី២.១០ ចំនួនគ្រួសារកសិកម្មដាំដំណាំផ្លែឈើ តាមប្រភេទដំណាំ នៅកម្ពុជា ឆ្នាំ២០២៥ ២៩
រូបទី២.១១ ចំនួនគ្រួសារដាំដំណាំស្វាយ បែងចែកតាមតំបន់ ឆ្នាំ២០២៥ ២៩
រូបទី២.១២ ផ្ទៃដីដាំដំណាំចេក បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៥ ៣០
រូបទី២.១៣ ចំនួនគ្រួសារកសិកម្មដាំដំណាំខ្នុរ តាមតំបន់ ឆ្នាំ២០២៥ ៣១
រូបទី២.១៤ ចំនួនគ្រួសារកសិកម្មដាំដំណាំស្វាយចន្ទីរ តាមតំបន់ ឆ្នាំ២០២៥ ៣២
រូបទី២.១៥ ផ្ទៃដីដាំដំណាំដូង បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៥ ៣២
រូបទី៣.១: ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វ បសុបក្សី តាមតំបន់ ឆ្នាំ២០២៥ ៣៧
រូបទី៣.២: ចំនួនគ្រួសារកសិកម្មចិញ្ចឹមគោ និងចំនួនគោ បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៣៩
រូបទី៣.៣: ចំនួនគ្រួសារកសិកម្មចិញ្ចឹមគោបែងចែកតាមហ្វូង ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៣៩
រូបទី៣.៤: ចំនួនគោ បែងចែងតាម អាយុ ភេទ ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៤០
រូបទី៣.៥: ចំនួនគោ បានកើត និងទិញ គិតតាមតំបន់ ឆ្នាំ២០២៥ ៤០
រូបទី៣.៦: ចំនួនបម្រែបម្រួលសត្វគោ ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៤១
រូបទី៣.៧: ចំនួនគ្រួសារ និងចំនួនសត្វក្របីបែងចែកតាមតំបន់ ឆ្នាំ២០២៥ ៤២
រូបទី៣.៨: ចំនួនគ្រួសារកសិកម្មចិញ្ចឹមក្របី បែងចែកតាមចំនួនហ្វូងប្រទេសកម្ពុជា ឆ្នាំ២០២៥ ៤៣
រូបទី៣.៩: ចំនួនសត្វក្របី បែងចែកតាម អាយុ ភេទ ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៤៤
រូបទី៣.១០: ចំនួនគ្រួសារចិញ្ចឹមជ្រូក និងចំនួនជ្រូកបែងចែកតាមតំបន់ ឆ្នាំ២០២៥ ៤៥
រូបទី៣.១១: ចំនួនគ្រួសារកសិកម្មចិញ្ចឹមជ្រូក បែងចែកតាមចំនួនជ្រូក ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៤៥
រូបទី៣.១២: ចំនួនសត្វជ្រូក បែងចែកតាមអាយុ និងភេទ ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៤៦
រូបទី៣.១៣: ចំនួនជ្រូក បានកើត និងទិញ បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៤៦
រូបទី៣.១៤: ចំនួនគ្រួសារកសិកម្មចិញ្ចឹមមាន់ បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៤៨
រូបទី៣.១៥: ចំនួនមាន់សរុប បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៤៩
រូបទី៣.១៦: ចំនួនមាន់បានកើត បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៤៩

រូបទី៣.១៧: បម្រែបម្រួលចំនួនមាន់ ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៥០
រូបទី៣.១៨: ចំនួនគ្រួសារកសិកម្មចិញ្ចឹមទា បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៥១
រូបទី៣.១៩: ចំនួនទាសរុប បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៥១
រូបទី៣.២០: ចំនួនទាបានកើត បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៥២
រូបទី៣.២១: បម្រែបម្រួលចំនួនទា ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៥២
រូបទី ៣.២២: ការអនុវត្តការផ្តល់ចំណីឱ្យសត្វរបស់គ្រួសារកសិកម្ម ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៥៣
រូបទី៣.២៣: ប្រភេទចំណីសត្វផ្តល់ឱ្យសត្វរបស់គ្រួសារកសិកម្ម ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៥៤
រូបទី៣.២៤:ប្រភពទឹកសំខាន់សម្រាប់ផ្តល់ឱ្យបសុសត្វរបស់គ្រួសារកសិកម្មប្រទេសកម្ពុជាឆ្នាំ២០២៥ ៥៤
រូបទី៣.២៥:ប្រភពទឹកសំខាន់សម្រាប់ផ្តល់ឱ្យបសុបក្សីរបស់គ្រួសារកសិកម្មប្រទេសកម្ពុជាឆ្នាំ២០២៥ ៥៥
រូបទី៣.២៦: ការថែទាំសត្វរបស់គ្រួសារកសិកម្ម ប្រទេសកម្ពុជា ឆ្នាំ២០២៥ ៥៥
រូបទី៤.១: ចំនួនគ្រួសារកសិកម្មដែលរាយការណ៍អំពីសកម្មភាពវារីវប្បកម្មតាមតំបន់ ឆ្នាំ២០២៥ ៥៧
រូបទី៤.២: ចំនួនគ្រួសារកាន់កាប់កសិកម្ម ដែលបានរាយការណ៍ពីសកម្មភាពវារីប្បកម្ម ឆ្នាំ២០២៥ ៥៨
រូបទី៤.៣: ចំនួនគ្រួសារកសិកម្ម ដែលរាយការណ៍អំពីសកម្មភាពនេសាទ បែងចែកតាមតំបន់ ឆ្នាំ២០២៥ ៥៩
រូបទី៤.៤: ចំនួនគ្រួសារកាន់កាប់កសិកម្មដែលពាក់ព័ន្ធសកម្មភាពផលត្រីនេសាទ នៅប្រទេសកម្ពុជា ឆ្នាំ២០២៥ (គិតតាមប្រភេទ) ៦០
រូបទី៤.៥: ការប្រៀបធៀបរវាងផលនេសាទក្នុងឆ្នាំបច្ចុប្បន្នទៅឆ្នាំមុន នៃគ្រួសារកសិកម្ម ឆ្នាំ២០២៥ ៦០
រូបទី៤.៦: ចំនួនគ្រួសារកាន់កាប់កសិកម្ម បានរាយការណ៍ពីឧបការណ៍នេសាទ ឆ្នាំ២០២៥ ៦១
រូបទី៥.១: ចំនួនសមាជិកគ្រួសារធ្វើការងារក្នុងកសិដ្ឋាន តាមតំបន់ ឆ្នាំ២០២៥ ៦៣
រូបទី៥.២: ចំនួនម៉ោងធ្វើការជាមធ្យមលើកសិដ្ឋានក្នុង១ឆ្នាំ តាមភេទ តាមតំបន់ ឆ្នាំ២០២៥ ៦៣
រូបទី៥.៣: ភាគរយនៃពេលវេលាបានចំណាយលើសកម្មភាពនីមួយៗ នៅកម្ពុជា ឆ្នាំ២០២៥ ៦៤
រូបទី៥.៤: ចំនួនកសិដ្ឋានបានជួលកម្មករពីខាងក្រៅ តាមតំបន់ ឆ្នាំ២០២៥ ៦៥
រូបទី៥.៥: ចំនួនកម្មករសរុបជួលពីខាងក្រៅ ធ្វើការពេញម៉ោង តាមភេទ នៅកម្ពុជា ឆ្នាំ២០២៥ ៦៥
រូបទី៥.៦: ចំនួនកសិដ្ឋានមានជួលកម្មករធ្វើការម្តងម្កាល តាមតំបន់ នៅកម្ពុជា ឆ្នាំ២០២៥ ៦៦
រូបទី៥.៧: ចំនួនកម្មករធ្វើការម្តងម្កាល តាមភេទ តំបន់ ឆ្នាំ២០២៥ ៦៦
រូបទី៥.៨: ប្រាក់ឈ្នួលជាមធ្យមក្នុង១ថ្ងៃសម្រាប់កម្មករធ្វើការម្តងម្កាល តាមតំបន់ឆ្នាំ២០២៥ ៦៧
រូបទី៥.៩: ប្រាក់ខែជាមធ្យមសម្រាប់កម្មករជួលពីខាងក្រៅធ្វើការពេញម៉ោង តាមតំបន់ឆ្នាំ២០២៥ ៦៨
រូបទី៥.១០: ចំនួនគ្រួសារកសិកម្មដែលធ្វើការឱ្យគ្រួសារកសិកម្មដទៃទៀតនៅតាមតំបន់ ឆ្នាំ២០២៥ ៦៩
រូបទី៥.១១: ការចំណាយលើប្រេងឥន្ធនៈអំឡុងរដូវប្រាំងនិងរដូវវស្សា (គិតជាដុល្លារ) តាមរដូវ និងតាមតំបន់ ឆ្នាំ២០២៥ ៦៩
រូបទី៥.១២: គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារកាន់កាប់កសិកម្ម នៅកម្ពុជា ឆ្នាំ២០២៥ ៧០

រូបទី៥.១៣: ភាគរយនៃប្រាក់ចំណូលពីកសិកម្មរួមចំណែកដល់ប្រាក់ចំណូលសរុបរបស់គ្រួសារ នៅកម្ពុជា ឆ្នាំ២០២៥	៧១
រូបទី៥.១៤: ការចូលរួមនៅក្នុងសមាគមកសិកររផ្លូវការ ឬសមាគមកសិករក្រៅផ្លូវការតាមតំបន់ ឆ្នាំ២០២៥	៧២
រូបទី៥.១៥: ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថាមានសមាជិកយ៉ាងតិចម្នាក់ដែលមានកម្ចីឥណទាន តាមតំបន់ ឆ្នាំ២០២៥	៧២
រូបទី៥.១៦: ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ថាបានប្រើប្រាស់កម្ចីឥណទានមួយចំនួនសម្រាប់គោលបំណងកសិកម្មតាមតំបន់ ឆ្នាំ២០២៥	៧៣
រូបទី៥.១៧: ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថាយ៉ាងហោចណាស់សមាជិកគ្រួសារម្នាក់មានប្រាក់កម្ចី តាមប្រភពនៃប្រាក់កម្ចី ឆ្នាំ២០២៥	៧៤
រូបទី៥.១៨: ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថាជួបគ្រោះហានិភ័យតាមតំបន់ឆ្នាំ២០២៥	៧៥
រូបទី៥.១៩: ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ថាបានទទួលរងគ្រោះហានិភ័យតាមប្រភេទគ្រោះហានិភ័យ ប្រទេសកម្ពុជា ឆ្នាំ២០២៥	៧៦
រូបទី៥.២០: ចំនួនគ្រួសារកសិកម្មដែលបានស្តារឡើងវិញពីគ្រោះហានិភ័យតាមតំបន់ឆ្នាំ២០២៥	៧៧
រូបទី៥.២១: ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍មធ្យោបាយចម្បង ដើម្បីទប់ទល់នឹងគ្រោះហានិភ័យ តាមតំបន់ ឆ្នាំ២០២៥	៧៨

បញ្ជីតារាង

តារាង១.១: សូចនាករសង្ខេបគ្រួសារកាន់កាប់កសិកម្ម	៤
តារាង១.២: សូចនាការសង្ខេបនៃផលិតកម្មដំណាំ	៥
តារាង១.៣: សូចនាករសង្ខេបនៃផលិតកម្មបសុសត្វ បសុបក្សី	៦
តារាង១.៤: សូចនាករសង្ខេបនៃសកម្មភាពវារីវប្បកម្ម និងនេសាទ	៧
តារាង១.៥: សូចនាករសង្ខេបនៃសកម្មភាពសេដ្ឋកិច្ច	៨
តារាង១.៦: ការបែងចែកសំណាកគំរូ	១៣
តារាង៣.១: ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វ និងបសុបក្សី (គិតជាពាន់)	៣៧

បញ្ជីផែនទី

ផែនទី២.១: គ្រួសារដែលមានដីកសិកម្មតិចជាង ២ហិកតា គិតជាភាគរយ បែងចែកតាមខេត្ត ឆ្នាំ២០២៥ ១៩

ផែនទី២.២: ទិន្នន័យផលស្រូវធម្មតា បែងចែកតាមខេត្ត ឆ្នាំ២០២៥ ២៤

ផែនទី២.៣: ទិន្នផលស្រូវក្រអូប បែងចែកតាមខេត្ត ឆ្នាំ២០២៥ ២៥

ផែនទី២.៤: ទិន្នផលដំឡូងមី បែងចែកតាមខេត្ត ឆ្នាំ២០២៥ ២៦

ផែនទី២.៥: ផលិតកម្មដំណាំស្វាយនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ឆ្នាំ២០២៥ ៣០

ផែនទី៣.១: គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទធំ (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៥ ៣៨

ផែនទី៣.២: គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុបក្សី (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៥ ៤៧

ផែនទី៥.១: គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាចំណូលពីកសិកម្មរួមចំណែក៦០%-១០០% នៃចំណូលសរុបរបស់គ្រួសារ (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៥ ៧១

ផែនទី៥.២: គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាបានទទួលកម្ចី សម្រាប់ប្រើប្រាស់ក្នុងគោលបំណងធ្វើកសិកម្ម (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៥ ៧៣

ផែនទី៥.៣: គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាជួបគ្រោះហានិភ័យ (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៥ ៧៥

ផែនទី៥.៤: គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាជួបគ្រោះរាំងស្ងួតជាគ្រោះមហន្តរាយ (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៥ ៧៦

ឧបសម្ព័ន្ធ

តារាងទី១: ផ្ទៃដីបានដាំដុះដំណាំ គិតជា ហិកតា ៧៩

តារាងទី២: ផ្ទៃដីបានដាំដុះដំណាំស្រូវ គិតជា ហិកតា ៨០

តារាងទី៣: ចំនួនបសុសត្វនិងបសុបក្សី បែងចែកតាមគ្រួសារកសិកម្ម និងសហគ្រាសកសិកម្មខ្នាតធំគិតជាចំនួនក្បាល ៨១

តារាងទី៤: វ៉ារីវប្បកម្ម បែងចែកតាមគ្រួសារកសិកម្ម គិតជាគីឡូក្រាម ៨២

តារាងទី៥: ផ្ទៃដីបានដាំដុះ និងប្រមូលផល បែងចែកតាមមុខដំណាំសំខាន់ៗ គិតជាហិកតា ៨៤

បុព្វកថា

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ផ្តល់ប្រភពទិន្នន័យយ៉ាងសំខាន់សម្រាប់ការវាយតម្លៃផលិតភាពកសិកម្មនៅកម្ពុជានិងបង្ហាញស្ថានភាព ស្តីពីផ្នែកដំណាំ ការចិញ្ចឹមសត្វ ការធ្វើវារីវប្បកម្ម ការនេសាទ និងសកម្មភាពពាក់ព័ន្ធដទៃទៀតដែលមានសារៈប្រយោជន៍ឆ្លុះបញ្ចាំងពីស្ថានភាពកសិកម្ម បរិស្ថាន សេដ្ឋកិច្ច សង្គម និងសន្តិសុខស្បៀងរបស់គ្រួសារកសិកម្មកម្ពុជា។ លើសពីនេះ ទិន្នន័យអង្កេតកសិកម្មកម្ពុជាជាធាតុចូលដ៏សំខាន់សម្រាប់ការវាស់វែង និងឆ្លុះបញ្ចាំងនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មការកាត់បន្ថយភាពក្រីក្រ ការគណនាកំណើនសេដ្ឋកិច្ចជាតិ និងកម្មវិធីអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងៗទៀត។

គោលបំណងសំខាន់នៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ដើម្បីជួយជំរុញទិសដៅការអភិវឌ្ឍវិស័យកសិកម្មក្នុងកិច្ចរួមចំណែកដល់ភាពរីកចម្រើនរបស់ប្រទេសជាតិ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជាឆ្ពោះទៅសម្រេចបានគោលដៅសំខាន់ៗ ចំនួនបីនៃក្របខ័ណ្ឌគោលដៅអភិវឌ្ឍនប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ ដូចខាងក្រោម៖

- គោលដៅទី១ ៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង
- គោលដៅទី២ ៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើង ស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព
- គោលដៅទី៥ ៖ សម្រេចឱ្យបានសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី និងកុមារីគ្រប់រូប។

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ នឹងផ្តល់ជូននូវព័ត៌មាននិងទិន្នន័យស្ថិតិអំពីស្ថានភាពវិស័យកសិកម្មដល់គ្រប់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិ ស្ថាប័នស្រាវជ្រាវ វិស័យឯកជន និងសាធារណជនទូទៅដែលអាចប្រើប្រាស់របកគំហើញទាំងនេះ តាមតម្រូវការ។ ទិន្នន័យអង្កេតកសិកម្មកម្ពុជានេះ នឹងបម្រើជាមូលដ្ឋានសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងបរិស្ថានល្អដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជាសម្រាប់ឆ្នាំ២០៥០ ដែលចាត់ទុកការអភិវឌ្ឍវិស័យកសិកម្មជាយុទ្ធសាស្ត្របញ្ជាកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) និងដៃគូអភិវឌ្ឍនានា ដែលបានរួមចំណែកក្នុងការធ្វើឱ្យការងាររង្កេតកសិកម្មកម្ពុជាបញ្ចប់ទៅប្រកបដោយជោគជ័យ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះថ្នាក់ដឹកនាំ អ្នកគ្រប់គ្រង មន្ត្រីជំនាញវិភាគរបាយការណ៍លទ្ធផលទិន្នន័យតាមផ្នែកនីមួយៗ និងក្រុមការងារបច្ចេកទេសអង្កេតកសិកម្មកម្ពុជា មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលបានចូលរួមខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ក្នុងដំណើរការអនុវត្តការងាររង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ និងសូមអរគុណចំពោះប្រជាពលរដ្ឋ ដែលបានចូលរួមសម្ភាសន៍ផ្តល់ចម្លើយធ្វើឱ្យអង្កេតកសិកម្មកម្ពុជាឈានសម្រេចបានជោគជ័យ។

ថ្ងៃច័ន្ទ ៧រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៦

រដ្ឋមន្ត្រីក្រសួងផែនការ

ចិន ត្រឈៃ

អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានបង្ហាញជូននូវ របាយការណ៍វិភាគលទ្ធផលចុងក្រោយអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ដែលទទួលបានពីការសម្ភាស សំណាកគំរូគ្រួសារកសិកម្មប្រមាណ ១៦ ០០០គ្រួសារ ២៥រាជធានី ខេត្ត នៅទូទាំងប្រទេសកម្ពុជា។ អង្កេត កសិកម្មកម្ពុជាឆ្នាំ២០២៥ គឺជាអង្កេតប្រចាំឆ្នាំលើកទី៧ នៅក្នុងការធ្វើអង្កេតបន្តបន្ទាប់ (គិតចាប់ពីឆ្នាំ ២០១៩ ឆ្នាំ២០២០ ឆ្នាំ២០២១ ឆ្នាំ២០២២ ឆ្នាំ២០២៣ ឆ្នាំ២០២៤ និងឆ្នាំ២០២៥)។

របាយការណ៍វិភាគលទ្ធផលនៃការអង្កេតនេះត្រូវបានដឹកនាំប្រតិបត្តិដោយវិទ្យាស្ថានជាតិស្ថិតិនៃ ក្រសួងផែនការមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេសពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានអនុវត្តដោយអនុលោមតាមកិច្ចព្រមព្រៀងរវាង ក្រសួង ផែនការ អង្គការស្បៀងនិងកសិកម្ម នៃសហប្រជាជាតិប្រចាំកម្ពុជានៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ។ អង្កេត កសិកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានធ្វើសម្ភាសន៍ផ្ទាល់ដោយប្រើប្រាស់ម៉ាស៊ីនថេប្លេត(Tablet) ដោយប្រើកម្មវិធី Survey Solution របស់ធនាគារពិភពលោកសម្រាប់កត់ត្រាសម្ភាសន៍ និងគ្រប់គ្រងទិន្នន័យ។

ទិន្នន័យដែលប្រមូលបានពីគ្រួសារកសិកម្មត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍វិភាគចុងក្រោយ នៃ ការអង្កេតនេះមានដូចជា៖ ផលិតកម្មដំណាំ បសុសត្វ បសុបក្សី វារីវប្បកម្ម ការនេសាទ និងកម្លាំងពលកម្ម និងសកម្មភាពសេដ្ឋកិច្ច ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិកសិកម្មប្រចាំឆ្នាំ និងបំពេញតម្រូវការរបស់អ្នកធ្វើ គោលនយោបាយ របាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍កសិកម្ម បរិស្ថាន និងសូចនាករគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពឆ្នាំ២០៣០ របស់រាជរដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ អ្នកសិក្សាស្រាវជ្រាវ និង អ្នកពាក់ព័ន្ធដទៃទៀត។

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ គឺជាធាតុចូលមួយដ៏សំខាន់ក្នុងការរៀបចំគោលនយោបាយ កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មដែលមានប្រសិទ្ធភាព ប្រសិទ្ធផល និងគាំទ្រសូចនាករគោលដៅឆ្ពោះទៅរក "យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១" របស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបានគោលដៅរំពឹងទុកសម្រាប់ "ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"។

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានបើកចំហសម្រាប់ការពិភាក្សា ព្រមទាំងទទួល នូវមតិយោបល់ ឬអនុសាសន៍នានា ដើម្បីកែលម្អរបាយការណ៍លទ្ធផលវិភាគអង្កេតកសិកម្មនាពេលអនាគត ឱ្យកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន គណៈកម្មការបច្ចេកទេសអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ជំនាញការអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមអនុវត្តន៍ការងារប្រមូល ចងក្រង វិភាគទិន្នន័យស្ថិតិសរសេររបាយការណ៍លទ្ធផលចុងក្រោយឱ្យសម្រេចបានជោគជ័យប្រកបដោយគុណភាព និងប្រសិទ្ធភាព។

ថ្ងៃច័ន្ទ ៧រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៦

ឯកឧត្តមបណ្ឌិត
ណោ ង៉ាន់ឌី

អក្សរកាត់

CAS	អង្កេតកសិកម្មកម្ពុជា Cambodia Agriculture Survey
CIAS	អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា Cambodia Inter-Censal Agriculture Survey
CSES	អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា Cambodia Socio-Economic Survey
FAO	អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ Food and Agriculture Organization
GDP	ផលិតផលក្នុងស្រុកសរុប Gross Domestic Product
Ha	ហិកតា Hectare
Kg	គីឡូក្រាម Kilograms
MAFF	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ Ministry of Agriculture Forestry and Fisheries
MOP	ក្រសួងផែនការ Ministry of Planning
NIS	វិទ្យាស្ថានជាតិស្ថិតិ National Institute of Statistics
PPS	ទំហំសមាមាត្រចៃដន្យ Probability Proportional to Size
RGC	រាជរដ្ឋាភិបាលកម្ពុជា Royal Government of Cambodia
TC	គណៈកម្មាធិការបច្ចេកទេស Technical Committee
USD	ដុល្លារអាមេរិក United States Dollar

ចេតនាសម្ព័ន្ធរបាយការណ៍

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានចែកជាប្រាំផ្នែកនៃរបាយការណ៍ដែលគ្របដណ្តប់នូវទិដ្ឋភាពសំខាន់ៗផ្សេងគ្នាដូចខាងក្រោម៖

ផ្នែកទី១៖ វិធីសាស្ត្រប្រមូលទិន្នន័យ និងឯកសារយោង

ផ្នែកនេះគ្របដណ្តប់នូវព័ត៌មាន នៃការអង្កេតទាំងមូលរួមមាន៖ បុព្វកថា អារម្ភកថា អក្សរកាត់ សូចនាករ សង្ខេបនៃវិធីសាស្ត្រអង្កេត វិសាលភាពនៃការអង្កេត ទីតាំងភូមិសាស្ត្រ រយៈពេលនៃការអង្កេត កាលបរិច្ឆេទយោង និងតារាងបញ្ជីសំណាកគំរូ។

ផ្នែកទី២៖ ផលិតកម្មដំណាំ

ផ្នែកនេះគ្របដណ្តប់លើផលិតកម្មដំណាំក្នុងប្រទេសកម្ពុជា រួមបញ្ចូលទាំងព័ត៌មានទាក់ទងនឹងចំនួនគ្រួសារកាន់កាប់កសិកម្ម ផលិតកម្មដំណាំរយៈពេលខ្លី និងដំណាំរយៈពេលវែង។ ការប្រើប្រាស់ផ្ទៃដីកសិកម្ម ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល ទិន្នផលដំណាំ ការប្រើប្រាស់ជី ប្រព័ន្ធធារាសាស្ត្រ ប្រភេទគ្រាប់ពូជ/ពូជរុក្ខជាតិដាំដុះ ប្រភេទដីដែលប្រើប្រាស់ ផលប៉ះពាល់នៃសំណឹកដី និងតម្លៃនៃការលក់ផលិតផលដំណាំ។

ផ្នែកទី៣៖ ការចិញ្ចឹមបសុសត្វ បសុបក្សី

ផ្នែកនេះគ្របដណ្តប់លើការកាន់កាប់គ្រួសារកសិកម្ម រួមបញ្ចូលទាំងចំនួនគ្រួសារចិញ្ចឹមបសុសត្វ និងបសុបក្សី ចំនួនសត្វសរុបនៅក្នុងប្រទេសកម្ពុជា ចំនួនសត្វជាមធ្យមក្នុងមួយគ្រួសារ គោលបំណងនៃការចិញ្ចឹមសត្វ តម្លៃនៃការលក់សត្វ និងថ្លៃដើមផលិត។

ផ្នែកទី៤៖ វារីវប្បកម្ម និងនេសាទ

ផ្នែកនេះគ្របដណ្តប់លើការកាន់កាប់គ្រួសារកសិកម្ម ដែលពាក់ព័ន្ធនឹងវារីវប្បកម្ម និងនេសាទ រួមបញ្ចូលទាំងចំនួនគ្រួសារធ្វើវារីវប្បកម្មតាមប្រភេទផ្សេងៗគ្នា ចំនួនផ្ទៃដីសរុបសម្រាប់វារីវប្បកម្ម ប្រភេទវារីសត្វចិញ្ចឹម និងបរិមាណផលិតគ្រួសារចូលរួមក្នុងសកម្មភាពនេសាទតាមប្រភេទទឹក ប្រភេទវារីសត្វ និងបរិមាណសរុបនេសាទបាន។

ផ្នែកទី៥៖ សេដ្ឋកិច្ច និងកម្លាំងពលកម្ម

ផ្នែកនេះគ្របដណ្តប់លើការកាន់កាប់របស់គ្រួសារកសិកម្ម ដែលពាក់ព័ន្ធកម្លាំងពលកម្មរួមបញ្ចូលទាំងព័ត៌មានស្តីពីសមាជិកគ្រួសារ និងពលករខាងក្រៅក្នុងកសិដ្ឋាន ការជួលដី ថ្លៃទិញ និងថ្លៃជួលដី ការចំណាយផ្សេងៗរបស់កសិដ្ឋាន តម្លៃផលិតផលកសិកម្ម ទិសដៅនៃផលិតកម្មកសិកម្ម ប្រាក់ឈ្នួលរបស់ពលករខាងក្រៅផលចំណេញរបស់កសិដ្ឋាន ការចូលរួមនៅក្នុងសមាគមន៍កសិករ ផលប៉ះពាល់ទៅលើកសិដ្ឋាន និងវិធានការឆ្លើយតបទៅនឹងផលប៉ះពាល់ទាំងនោះ រួមទាំងការធានារ៉ាប់រង និងឥណទាន ព្រមទាំងប្រាក់កម្ចី និងការសន្សំប្រាក់។

ផ្នែកទាំង៥ខាងលើអាចទាញយកពីគេហទំព័រ *http://www.nis.gov.kh/index.php/km* របស់វិទ្យាស្ថានជាតិស្ថិតិ ក្នុងគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅ នៃទិន្នន័យដែលមាននៅក្នុងការអង្កេតកសិកម្មឆ្នាំ២០២៥។ ការសរសេររបាយការណ៍វិភាគនេះ បានដកស្រង់យកចំណុចសំខាន់ៗ ហើយទិន្នន័យបង្ហាញតែនៅកម្រិតថ្នាក់ជាតិ និងតំបន់។ អ្នកប្រើប្រាស់ទិន្នន័យត្រូវបានលើកទឹកចិត្តអាចស្វែងរកដោយខ្លួនឯង ដោយប្រើតារាងទិន្នន័យលម្អិតដែលត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រទិន្នន័យ **CAMSAT** *https://camstat.nis.gov.kh* និង **Microdata** *https://microdata.nis.gov.kh* ។



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ផ្នែកទី១: ទិដ្ឋភាពសង្ខេប













Food and Agriculture Organization of the United Nations

ទិន្នាស្ថានជាតិស្ថិតិ ក្រសួងផែនការ

សហការជាមួយ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

ផ្នែកទី១ វិធីសាស្ត្រអង្កេត

រចនាសម្ព័ន្ធសង្ខេប

អង្កេតកសិកម្មកម្ពុជាត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០២៥ ក្នុងគោលបំណងដើម្បីប្រមូល ចងក្រងព័ត៌មាន វិភាគទិន្នន័យស្ថិតិកសិកម្មស៊ីជម្រៅក្នុងផ្នែកការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី ការធ្វើវារីវប្បកម្ម និងការនេសាទ។ ទិន្នន័យស្ថិតិដែលប្រមូលបានពីការអង្កេតនេះផ្តល់សារៈប្រយោជន៍ដល់អ្នករៀបចំធ្វើផែនការគោលនយោបាយ និងកម្មវិធីអភិវឌ្ឍនានាសម្រាប់ការលើកកម្ពស់គុណភាពវិស័យកសិកម្ម និងនេសាទនៅប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នរបស់រដ្ឋាភិបាល ដែលមានតួនាទីទទួលខុសត្រូវ និងបានទទួលការអនុញ្ញាតឱ្យធ្វើការអង្កេតនេះ។ វិទ្យាស្ថានជាតិស្ថិតិមានតួនាទី និងភារកិច្ចក្នុងការប្រមូល ចងក្រង វិភាគទិន្នន័យស្ថិតិតាមរយៈការធ្វើជំរឿន និងអង្កេតនានា ដោយឡែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ជាចម្បងនូវទិន្នន័យអង្កេតនេះ។

គោលបំណងចម្បង នៃការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ដើម្បីផ្តល់ទិន្នន័យស្តីពីស្ថានភាពវិស័យកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ដល់អ្នករៀបចំផែនការ កសាងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍផ្សេងៗរបស់រាជរដ្ឋាភិបាល និងវិស័យឯកជន។ បន្ទាប់ពីអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ នឹង២០២០ ដែលបានប្រើប្រាស់បញ្ជីសំណាកគំរូតែមួយដូចគ្នា អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ឆ្នាំ២០២២ និងឆ្នាំ២០២៣ បានប្រើប្រាស់បញ្ជីសំណាកគំរូតែមួយដូចគ្នា ដោយឡែកការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ និងឆ្នាំ២០២៥ ដែលបានប្រើប្រាស់សំណាកគំរូយកចេញពីជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានប្រើប្រាស់វិធីសាស្ត្រស្ថិតិ ដើម្បីជ្រើសរើសភូមិសំណាកគំរូនៅទូទាំងប្រទេសកម្ពុជា (CAS 2023 Sampling Frame)។

ការប្រមូលទិន្នន័យអង្កេតនេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍អ្នកផ្តល់ចម្លើយដោយផ្ទាល់ និងប្រើប្រាស់ម៉ាស៊ីនថេប្លេត។ បញ្ជីសំណួរសម្រាប់ការអង្កេតនេះត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីអង្កេត (Survey Solutions) របស់ធនាគារពិភពលោក។ ការប្រើប្រាស់កម្មវិធីកាពី (CAPI) សម្រាប់សម្ភាសន៍ គឺចំណេញពេលវេលា មិនចំណាយលើការវាយបញ្ចូលទិន្នន័យ បង្កើនសមត្ថភាពចំណេះដឹងជំនាញលើបច្ចេកវិទ្យាកុំព្យូទ័រ និងការត្រួតពិនិត្យគុណភាព និងមានលទ្ធភាពទាញតារាងស្ថិតិធ្វើការវិភាគទិន្នន័យបានឆាប់រហ័សជាងមុន។

សំណាកគំរូគ្រួសារកសិកម្ម ដែលរស់នៅទូទាំងប្រទេសត្រូវបានជ្រើសរើសយកមកធ្វើការសម្ភាស ដោយផ្តោតជាពិសេសទៅលើគ្រួសារដែលបានចូលរួមសកម្មភាពកសិកម្ម លើកលែងតែគ្រួសារដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ ត្រូវបានដកចេញពីជំរឿនចំពោះភូមិដែលមានគ្រួសារកសិកម្មតិចជាង ៥គ្រួសារយោងទៅតាមទិន្នន័យជំរឿនប្រជាជនឆ្នាំ២០១៩។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ សំណាកគំរូសរុបចំនួន ១៥ ៤០៥គ្រួសារកសិកម្មត្រូវបានសម្ភាសន៍ពេញលេញ។

បន្ថែមពីលើការប្រមូលទិន្នន័យតាមលក្ខណៈគ្រួសារកសិកម្ម ទិន្នន័យដាច់ដោយឡែកមួយទៀតត្រូវបានប្រមូលលើសហគ្រាសកសិកម្មខ្នាតធំ ដែលគ្រប់គ្រងដោយសាជីវកម្ម សហករណ៍ និងស្ថាប័នរដ្ឋាភិបាល ឬឯកជន ដែលសំដៅដល់ការកាន់កាប់មិនមែនលក្ខណៈគ្រួសារ ការប្រមូលនេះត្រូវបានសម្ភាសន៍គ្រប់សហគ្រាសកសិកម្មខ្នាតធំទាំងអស់ ដែលមានចំនួនសរុប ៤៧៦សហគ្រាស ត្រូវបានសម្ភាសន៍ពេញលេញនៅក្នុងការប្រមូលទិន្នន័យអង្កេតកសិកម្មឆ្នាំ២០២៥។

ព័ត៌មានលម្អិតអំពីនីតិវិធីនៃការជ្រើសរើស សំណាកគំរូ វិធីសាស្ត្រអង្កេត និងប្រតិបត្តិការប្រមូលទិន្នន័យសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ មានការអធិប្បាយពន្យល់លម្អិតនៅក្នុងជំពូកទី១ – វិសាលភាពការគ្របដណ្តប់ និងការជ្រើសរើសសំណាកគំរូ។ ការសម្ភាសគ្រួសារកសិកម្មបានធ្វើឡើងចាប់ពីខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយកំណត់កាលបរិច្ឆេទយោងគឺក្នុងរយៈពេល១២ខែកន្លងមក ដោយគិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ មានមន្ត្រីសម្ភាសន៍សរុបចំនួន ៤០០នាក់ ចូលរួមក្នុងការងារ និងមន្ត្រីត្រួតពិនិត្យចំនួន ៩២នាក់ ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពទិន្នន័យ សម្របសម្រួល ដោះស្រាយបញ្ហានៅតាមមូលដ្ឋាន ទំនាក់ទំនងជាមួយប្រធានភូមិ និងគ្រួសារកាន់កាប់ កសិកម្ម។ មន្ត្រីចូលរួមអង្កេតកសិកម្មឆ្នាំ២០២៥នេះ បានជ្រើសរើសចេញពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីនៅតាមមន្ទីរផែនការ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរាជធានី ខេត្ត។

ការអង្កេតកសិកម្មកម្ពុជាបានប្រើប្រាស់និយមន័យ "គ្រួសារកាន់កាប់កសិកម្ម" ដែលកំណត់ក្នុងឯកសារណែនាំស្តីអំពីជំរឿនកសិកម្មពិភពលោកដែលបានបោះផ្សាយឆ្នាំ២០២០ (WCA 2020) និងយុទ្ធសាស្ត្រសកលដើម្បីលើកកម្ពស់ស្ថិតិកសិកម្ម និងជនបទ។ ការកាន់កាប់កសិកម្មត្រូវបានកំណត់ថា៖ ជាអង្គភាពសេដ្ឋកិច្ច នៃផលិតកម្មកសិកម្មស្ថិតក្រោមការគ្រប់គ្រងតែមួយ ដែលរួមមាន បសុសត្វ បសុបក្សី ដែលបានរក្សាទុក និងផ្ទៃដីដែលបានប្រើប្រាស់ទាំងស្រុង ឬមួយផ្នែកសម្រាប់គោលបំណងផលិតកម្មកសិកម្ម ដោយមិនគិតពីស្ថានភាពកម្មសិទ្ធិ ទម្រង់នៃការកាន់កាប់ ឬទំហំឡើយ។ ការគ្រប់គ្រងណាមួយ អាចត្រូវបានអនុវត្តន៍ដោយបុគ្គលឬគ្រួសារ ដោយបុគ្គលពីរនាក់ ច្រើននាក់ ឬច្រើនគ្រួសាររួមគ្នា ជាក្រុម ឬកុលសម្ព័ន្ធ ឬដោយនីតិបុគ្គលដូចជា សាជីវកម្ម សហគមន៍ ឬស្ថាប័នរដ្ឋាភិបាល។ ដីដែលស្ថិតនៅក្រោមការកាន់កាប់កសិកម្ម អាចមានក្បាលដីមួយ ឬច្រើន ដែលមានទីតាំងនៅតំបន់ដាច់ដោយឡែកមួយឬច្រើន ឬនៅក្នុងភូមិសាស្ត្រ ឬរដ្ឋបាលដែនដីមួយឬច្រើន ដោយផ្តល់ក្បាលដី ដែលមានមធ្យោបាយផលិតកម្មដូចគ្នា ដូចជា ពលកម្ម អគារកសិដ្ឋាន គ្រឿងយន្ត ឬកម្លាំងអូសទាញ។ វិសាលភាពនៃសកម្មភាពកសិកម្មមានដូចជាការដាំដំណាំរយៈពេលវែង ឬដំណាំរយៈពេលខ្លី ការបង្កាត់ពូជរុក្ខជាតិ ផលិតកម្មសត្វ ឬការធ្វើកសិកម្មចម្រុះ។ សកម្មភាពសេដ្ឋកិច្ចមិនមែនកសិកម្មផ្សេងទៀត ដូចជា វារីវប្បកម្ម ការនេសាទ និងព្រៃឈើ ត្រូវបានចាត់ទុកថាជាពិពិធកម្មនៃការកាន់កាប់កសិកម្ម។ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២៥ គ្រួសារកសិកម្មសំដៅទៅលើគ្រួសារដែលបានដាំដំណាំលើផ្ទៃដីយ៉ាងហោចណាស់ ០,០៣ហិកតា និង/ឬមានបសុសត្វធំចំនួន ២ និង/ឬ បសុសត្វតូចចំនួន ៣ និង/ឬ បសុបក្សី ២៥ក្បាល។

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ គឺជាការជ្រើសរើសសំណាកគំរូមានកម្រិតកំណត់ ដូច្នេះទិន្នន័យដែលផលិត វិភាគ បកស្រាយ ឬអាចប្រៀបធៀបជាមួយប្រភពទិន្នន័យផ្សេងៗ ប៉ុន្តែអ្នកប្រើប្រាស់ និងអ្នកអាន

សូមពិនិត្យនីតិវិធី ឬខ្លឹមសារដែលមានក្នុងផ្នែកទី១ នៃរបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥។ ជាទូទៅអ្នកប្រើប្រាស់ទិន្នន័យ ឬអ្នកអាន គួរស្វែងយល់ពីដែនកំណត់ វិសាលភាពនៃអង្កេតកសិកម្ម និងការកាន់កាប់កសិកម្មនៅកម្ពុជា។

សូចនាករសង្ខេប

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ប្រើប្រាស់កម្រងសំណួរជាចម្បងមួយសម្រាប់ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារហើយកម្រងសំណួរដូចគ្នានេះ ក៏ត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំផងដែរ។

ទម្រង់កម្រងសំណួរនេះរួមមាន១៣ជំពូកសំខាន់ៗគឺ៖

១. អត្តសញ្ញាណនៃអ្នកតបសម្ភាសន៍ និងការណែនាំខ្លួនស្នើសុំការសម្ភាស
២. សមាជិកគ្រួសារ
៣. ចរិតលក្ខណៈនៃគ្រួសារ/កសិដ្ឋាន
៤. ការកាន់កាប់ដី និងការអនុវត្តកសិកម្ម
៥. ផលិតកម្មដំណាំ
៦. ការប្រើប្រាស់គ្រាប់ពូជ ការអនុវត្តកសិកម្ម និងធាតុចូល
៧. ផលិតកម្មបសុសត្វ
៨. ផលិតកម្មបសុបក្សី
៩. វារីវប្បកម្ម និង/ឬការនេសាទត្រី
១០. សកម្មភាពសេដ្ឋកិច្ច
១១. ការប្រើប្រាស់កម្លាំងពលកម្ម
១២. យុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈម និងការបម្រែបម្រួលអាកាសធាតុ ឬបរិស្ថាន
១៣. បញ្ចប់ការសម្ភាស

ទិន្នន័យសំខាន់ៗកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់ ទាញចេញពីការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បែងចែកតាមតំបន់ វាលទំនាប បឹងទន្លេសាប ឆ្នេរសមុទ្រ និង ភ្នំនិងខ្ពង់រាប ត្រូវបានបង្ហាញក្នុងតារាងដូចខាងក្រោម៖

តារាងទី១.១៖ សូចនាករសង្ខេប គ្រួសារកាន់កាប់កសិកម្ម

គ្រួសារកាន់កាប់កសិកម្ម					
	ប្រទេសកម្ពុជា	**តំបន់វាលទំនាប**	**តំបន់បឹងទន្លេសាប**	**តំបន់ឆ្នេរសមុទ្រ**	**តំបន់ភ្នំ និងខ្ពង់រាប**
ចំនួនគ្រួសារកសិកម្ម (គិតជាពាន់)	១ ៨៧៥	៧២២	៧៣៥	១២២	២៩៧
គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារកសិកម្ម៖					
ចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ	៣0%	២៩%	២៩%	៤៧%	២៨%
ចម្បងសម្រាប់លក់	៤២%	៣៧%	៥0%	២0%	៤១%
ភាគរយនៃគ្រួសារកសិកម្មមានតែដីជុំវិញលំនៅឋានប៉ុណ្ណោះ	៩%	៨%	១១%	១0%	៤%

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

តារាងទី១.២ សូចនាករសង្ខេបនៃផលិតកម្មដំណាំ

ផលិតកម្មដំណាំ					
	ប្រទេសកម្ពុជា	**តំបន់វាលទំនាប**	**តំបន់បឹងទន្លេសាប**	**តំបន់ឆ្នេរសមុទ្រ**	**តំបន់ភ្នំ និងខ្ពង់រាប**
ចំនួនគ្រួសារបានដាំដុះដំណាំ (គិតជាពាន់)	១ ៧៥៨	៦៨៥	៦៧០	១១៥	២៨៨
ភាគរយនៃគ្រួសារបានដាំដុះដំណាំ	៩៤%	៩៥%	៩១%	៩៤%	៩៧%
ដំណាំដែលពេញនិយមចំនួនប្រាំដែលបានដាំដុះដោយគ្រួសារកសិកម្ម	១. ស្រូវធម្មតា	១. ស្រូវធម្មតា	១. ស្រូវធម្មតា	១. ស្រូវធម្មតា	១. ស្រូវធម្មតា
	២.ស្វាយ	២. ចេក	២. ស្វាយ	២. ដូង	២. ស្វាយចន្ទី
	៣. ដូង	៣. ដូង	៣. ចេក	៣. ស្វាយ	៣. ដំឡូងមី
	៤. ចេក	៤. ស្វាយ	៤. ដូង	៤. ចេក	៤. ស្វាយ
	៥. ស្រូវក្រអូប	៥. ស្រូវក្រអូប	៥. ស្រូវក្រអូប	៥. ស្រូវក្រអូប	៥. ដូង

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

តារាងទី១.៣ សូចនាករសង្ខេបនៃផលិតកម្មបសុសត្វ បសុបក្សី

សកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី					
	ប្រទេសកម្ពុជា	**តំបន់វាលទំនាប**	**តំបន់បឹងទន្លេសាប**	**តំបន់ឆ្នេរសមុទ្រ**	**តំបន់ភ្នំ និងខ្ពង់រាប**
ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមបសុសត្វ បសុបក្សី ក្នុងអំឡុងពេលឆ្នាំយោង (គិតជាពាន់)	១ ២៣០	៤៧០	៤៧៣	១០៣	១៨៤
ភាគរយនៃគ្រួសារកសិកម្មដែលបានចិញ្ចឹមបសុសត្វ/បសុបក្សី ក្នុងអំឡុងពេលឆ្នាំយោង	៦៥%	៦៥%	៦៤%	៨៥%	៦២%
ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមសត្វគោក្នុងអំឡុងពេលឆ្នាំយោង (គិតជាពាន់)	៦៣៩	២៦៦	២២៥	៥៤	៩៣
ចំនួនសត្វគោជាមធ្យមក្នុងមួយគ្រួសារ	៤.៤	៣.៨	៤.៧	២.៩	៦.៥
ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមសត្វមាន់ក្នុងអំឡុងពេលឆ្នាំយោង (គិតជាពាន់)	៨៨៧	៣២៧	៣៣៨	៩៥	១២៦
ចំនួនសត្វមាន់ជាមធ្យមក្នុងមួយគ្រួសារ	២៥	២៣	២៦	៣១	២៤

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

តារាងទី១.៤៖ សូចនាករសង្ខេបនៃសកម្មភាពវារីវប្បកម្ម និងនេសាទ

សកម្មភាពវារីវប្បកម្ម និងនេសាទ					
	ប្រទេសកម្ពុជា	**តំបន់វាលទំនាប**	**តំបន់បឹងទន្លេសាប**	**តំបន់ឆ្នេរសមុទ្រ**	**តំបន់ភ្នំ និងខ្ពង់រាប**
ចំនួនគ្រួសារកសិកម្មដែលបានចូលរួមធ្វើវារីវប្បកម្ម (គិតជាពាន់)	៦០	៣៩	១៥	៤	៣
ភាគរយគ្រួសារកសិកម្មដែលបានចូលរួមធ្វើវារីវប្បកម្ម	៣%	៥%	២%	៣%	១%
ចំនួនគ្រួសារកសិកម្មដែលបានចូលរួមសកម្មភាពនេសាទ (គិតជាពាន់)	៤០៩	១០០	២០៦	២៧	៧៦
ភាគរយគ្រួសារកសិកម្មដែលបានចូលរួមសកម្មភាពនេសាទ	២២%	១៤%	២៨%	២២%	២៥%

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

តារាងទី១.៥៖ សូចនាករសង្ខេបនៃសកម្មភាពសេដ្ឋកិច្ច

សកម្មភាពសេដ្ឋកិច្ច					
	ប្រទេសកម្ពុជា	**តំបន់វាលទំនាប**	**តំបន់បឹងទន្លេសាប**	**តំបន់ឆ្នេរសមុទ្រ**	**តំបន់ភ្នំ និងខ្ពង់រាប**
ភាគរយនៃគ្រួសារកសិកម្មដែលមានចំណូលបានមកពីសកម្មភាពកសិកម្មទាំងស្រុង	៦.២%	៣.៨%	៩.៣%	២.៤%	៦.២%
ការចូលរួមចំណែកចំណូលបានពីកសិកម្មជាមួយនឹងចំណូលសរុបគ្រួសារដោយប្រៀបធៀបទៅឆ្នាំមុន៖					
ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មទាបជាងឆ្នាំមុន	២៤%	២៤%	២៨%	២០%	១៦%
ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មប្រហែលគ្នាឆ្នាំមុន	៦៩%	៧០%	៦៥%	៦៩%	៧៦%
ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មច្រើនជាងឆ្នាំមុន	៧%	៦%	៦%	១១%	៨%

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ការអង្កេតចន្លោះជំជឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានប៉ាន់ស្មានគ្រួសារចំនួន ៣ ៧៣៥ ៦៥៩ គ្រួសារនៅកម្ពុជាឆ្នាំ២០២៥ ។ ដោយឡែកអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានប៉ាន់ប្រមាណថាមានគ្រួសារចំនួន ១ ៨៧៥ ៥២០ គ្រួសារដែលចូលរួមក្នុងវិស័យកសិកម្ម។ ដូច្នេះគ្រួសារប្រមាណ ៥០ ភាគរយ នៃគ្រួសារទាំងអស់នៅក្នុងប្រទេសកម្ពុជាបានចូលរួមក្នុងផលិតកម្មកសិកម្ម។ ការប៉ាន់ប្រមាណចំនួន ១០ ភាគរយ នៃគ្រួសារកាន់កាប់កសិកម្ម បានរាយការណ៍ពីសកម្មភាពកសិកម្មនៅលើដីជុំវិញលំនៅឋានតែប៉ុណ្ណោះ។ ដោយយោងទៅតាមការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានប៉ាន់ប្រមាណពីចំនួនមធ្យមនៃការកាន់កាប់ក្បាលដីក្បាលដីមានប្រមាណ ១,៨ ក្បាលដីក្នុងក្បាលដី។

ដំណាំសំខាន់ៗដែលបានដាំដុះគឺ (១) ស្រូវធម្មតា (២) ចេក (៣) ស្វាយ និង (៤) ដូង។ គ្រួសារកាន់កាប់កសិកម្មចំនួន ៦៥ ភាគរយ ត្រូវបានរាយការណ៍ថាមានសកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី ឬសត្វល្អិត។ គ្រួសារកសិកម្មចំនួន ៦៦៨ ៣៦០ ដែលបានចិញ្ចឹម គោ ក្របី ជាចម្បងក្នុងរយៈពេល១២ខែកន្លងមក។

១. ចំនួនគ្រួសារដោយផ្អែកលើការធ្វើអង្កេតចន្លោះជំរឿនប្រជាជននៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ អាចទាញយកបានតាមរយៈអាសយដ្ឋានដូចខាងក្រោម៖

https://www.nis.gov.kh/nis/CIPS/Cambodia%20Inter-censal%20Population%20 Survey%2024.pdf គ្រួសារកសិកម្មចំនួន ៩៤ភាគរយ ត្រូវបានរាយការណ៍ថាមានសកម្មភាពដាំដំណាំនៅទូទាំងប្រទេសកម្ពុជា។ គ្រួសារ

កសិកម្មចំនួន ៨៨៦ ៩២០គ្រួសារដែលបានរាយការណ៍ថាបានចិញ្ចឹមមាន់ជាចម្បងក្នុងរយៈពេល១២ ខែកន្លងមក។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានប៉ាន់ប្រមាណថា ៣ភាគរយ នៃគ្រួសារកសិកម្មបានចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង ២២ភាគរយ បានចូលរួមក្នុងសកម្មភាពនេសាទ។

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានសួរសំណួរអំពីសេដ្ឋកិច្ចជាច្រើនដល់អ្នកតបសម្ភាសន៍។ គ្រួសារកសិកម្មត្រូវបានស្នើសុំឱ្យប៉ាន់ស្មានពីចំណែកនៃប្រាក់ចំណូលសរុបក្នុងគ្រួសារ ដែលត្រូវបានគណនាដោយប្រាក់ចំណូលពីកសិកម្មរបស់ពួកគេ។ ការប៉ាន់ប្រមាណ ៦,២ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មក្នុងគ្រួសារទាំងអស់បានរាយការណ៍ថាប្រាក់ចំណូលសរុប របស់គ្រួសារទាំងអស់ត្រូវបានរាប់បញ្ចូលថាជាប្រាក់ចំណូលពីកសិកម្ម។

លើសពីនេះទៀត អ្នកតបសម្ភាសន៍ត្រូវបានស្នើសុំឱ្យប្រៀបធៀបប្រាក់ចំណូលកសិកម្មរបស់ពួកគេក្នុងអំឡុងពេលយោងទៅនឹងប្រាក់ចំណូលកសិកម្មរបស់ពួកគេក្នុងអំឡុងពេលឆ្នាំមុន។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានប៉ាន់ប្រមាណថា ២៤ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មក្នុងគ្រួសារបានរាយការណ៍ពីប្រាក់ចំណូលពីកសិកម្មទាបជាងឆ្នាំមុន ៦៩ភាគរយ បានរាយការណ៍ពីប្រាក់ចំណូលពីកសិកម្មស្រដៀងនឹងឆ្នាំមុន ហើយ ៧ភាគរយ បានរាយការណ៍ពីប្រាក់ចំណូលពីកសិកម្មច្រើនជាងឆ្នាំមុន។

ទំហំ វិសាលភាព និងការជ្រើសរើសសំណាកគំរូ

ការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ នៅកម្ពុជា គឺជាកិច្ចការ ប្រមូល និងចងក្រងព័ត៌មានស្ថិតិ មានលក្ខណៈស៊ីជម្រៅ ផ្តោតលើការដាំដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី ការធ្វើវារីវប្បកម្ម និងនេសាទ។ ទិន្នន័យដែលប្រមូលបានពីការអង្កេតនេះមានសារៈសំខាន់បំផុតសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំផែនការ គោលនយោបាយ កម្មវិធីអភិវឌ្ឍនានាដើម្បីលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជា។ អង្កេតកសិកម្មប្រចាំឆ្នាំ២០២៥ គឺជាការអង្កេតប្រចាំឆ្នាំលើកទីប្រាំពីរ គិតចាប់ពីធ្វើអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ នៅព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០១៩ ២០២០ ២០២១ ២០២២ ២០២៣ ២០២៤)។

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នរបស់រដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល និងមានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ នេះ។ វិទ្យាស្ថានជាតិស្ថិតិ មានតួនាទី និងភារកិច្ចធ្វើជំរឿន និងអង្កេត ដោយឡែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ទិន្នន័យចម្បងដែលផលិតចេញពីការអង្កេតនេះ។

គោលបំណង

ការអង្កេតកសិកម្មកម្ពុជានេះ មានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីសកម្មភាពកសិកម្មនៅកម្ពុជា ដែលប្រើប្រាស់ដោយអ្នករៀបចំផែនការ និងអ្នកកសាងគោលនយោបាយ។ ជាពិសេសទិន្នន័យអង្កេតនេះផ្តល់សារៈប្រយោជន៍៖

1. ការផ្តល់នូវបច្ចុប្បន្នភាពនៃបញ្ជីមេ Sampling Frame នៅក្នុងការធ្វើអង្កេតកសិកម្មកម្ពុជា

២. ការផ្តល់ទិន្នន័យនៅកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់ ក្នុងនោះទិន្នន័យមួយចំនួនក៏មាននៅថ្នាក់ខេត្ត
៣. ការផ្តល់ទិន្នន័យអំពីរចនាសម្ព័ន្ធបច្ចុប្បន្ននៃការកាន់កាប់កសិកម្មនៅកម្ពុជា ដូចជា ការដាំដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ព្រមទាំងការធ្វើសកម្មភាពវារីវប្បកម្ម និងនេសាទផងដែរ។

វិសាលភាពគ្របដណ្តប់ពេញលេញនៃការអង្កេតនេះ អាចត្រូវបានពិនិត្យនៅក្នុងព័ត៌មានលម្អិតនៃកម្រងសំណួរដែលមាននៅលើគេហទំព័រ (https://www.nis.gov.kh)។ ទិន្នន័យទាំងនេះបង្កើតសក្តានុពលសម្រាប់ការវិភាគទូលំទូលាយដែលអាចធំជាងវិសាលភាពនៃរបាយការណ៍នេះ។ គួរកត់សម្គាល់ថា របាយការណ៍នេះរួមបញ្ចូលទិន្នន័យនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងទិន្នន័យនៅថ្នាក់ខេត្ត ដែលមានជាតារាងលម្អិតនៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ (https://microdata.nis.gov.kh/index.php) ។

វិធីសាស្ត្រ

អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ និងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ គឺជាអង្កេតសំណាកគំរូដូចគ្នា ដោយប្រើប្រាស់វិធីសាស្ត្រ(Panel Approach)។ ដូចគ្នានេះដែរ អង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១ ២០២២ និងឆ្នាំ២០២៣ បានប្រើប្រាស់សំណាកគំរូតែមួយ ដោយប្រើវិធីសាស្ត្រ(Panel Approach) ដូចគ្នាដែរ។ ចំណែកឯ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ និង២០២៥ មិនមានសកម្មភាពចុះស្រង់បញ្ជីព័ត៌មានជាលក្ខណៈគ្រួសារទេ ប៉ុន្តែជំនួសមកវិញ ត្រូវបានជ្រើសរើសភូមិគំរូតំណាង ចេញពីបញ្ជីមេដែលស្ថិតនៅភូមិឬមណ្ឌលអង្កេតគំរូនៃជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣(CAC2023) ហើយគ្រួសារដែលមាននៅក្នុងភូមិគំរូតំណាងទាំងនេះ ត្រូវបានពិនិត្យ និងជ្រើសរើស ដោយសាគ្រួសារទាំងនេះបានចូលរួមក្នុងសកម្មភាពកសិកម្មណាមួយ ដោយផ្អែកលើព័ត៌មានចម្បង គ្រួសារកសិកម្មទាំងនេះត្រូវបានចែកជាចំណាត់ថ្នាក់ និងជាគ្រួសារគំរូដើម្បីជ្រើសរើសសម្រាប់ធ្វើការសម្ភាសន៍។

មន្ត្រីសម្ភាសន៍ត្រូវបានជ្រើសរើសមកពីមន្ទីរផែនការ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។ មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ (DS) ត្រូវបានជ្រើសរើសពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យទាំងអស់ត្រូវបានធ្វើការបណ្តុះបណ្តាលមុននឹងចុះប្រតិបត្តិការអង្កេតនេះ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួងទាំងពីរ បានធ្វើឡើងនៅទូទាំងប្រទេសកម្ពុជា ចាប់តាំងពីការប្រមូលទិន្នន័យរហូតដល់ការវិភាគ និងចងក្រងទិន្នន័យ។

ការប្រមូលទិន្នន័យអង្កេតនេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍អ្នកផ្តល់ចម្លើយដោយផ្ទាល់ និងប្រើប្រាស់ម៉ាស៊ីនថេប្លេត។ បញ្ជីសំណួរសម្រាប់ការអង្កេតនេះត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីអង្កេត (Survey Solutions) របស់ធនាគារពិភពលោក។ ការប្រើប្រាស់កម្មវិធីកាពី (CAPI) សម្រាប់សម្ភាសន៍ គឺចំណេញពេលវេលា មិនចំណាយលើការវាយបញ្ចូលទិន្នន័យ បង្កើនសមត្ថភាពចំណេះដឹងជំនាញលើបច្ចេកវិទ្យាកុំព្យូទ័រ និងការត្រួតពិនិត្យគុណភាព និងមានលទ្ធភាពទាញតារាងស្ថិតិធ្វើការវិភាគទិន្នន័យបានឆាប់រហ័សជាងមុន។

ទិសាលភាពនៃការអង្កេត

កម្រងសំណួរបានប្រមូលទិន្នន័យផ្តោតលើទិដ្ឋភាពមួយចំនួននៃការកាន់កាប់កសិកម្ម រួមទាំងព័ត៌មានប្រជាសាស្ត្រ សហកម្មសិទ្ធិករ សមាជិកគ្រួសារ សកម្មភាពផលិតកម្មដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី សកម្មភាពវារីវប្បកម្ម និងនេសាទ បរិស្ថាន ស្ថានភាពសេដ្ឋកិច្ចក្នុងអំឡុងពេល១២ខែកន្លងមក ដែលប្រើប្រាស់នៅក្នុងកសិដ្ឋាន ព័ត៌មានអំពីលំនៅឋាន និងទ្រព្យសម្បត្តិគ្រួសារ។

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥នេះ រួមបញ្ចូលម៉ូឌុលដែលមាននៅក្នុងអង្កេតកសិកម្មឆ្នាំ២០២១ ដែលម៉ូឌុលសំខាន់មានប្រាក់ចំណូលការងារ និងផលិតភាព (ILP) នៅក្នុងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១។

ទីតាំងភូមិសាស្ត្រគ្របដណ្តប់

សំណាកគំរូគ្រួសារកសិកម្ម ដែលរស់នៅទូទាំងប្រទេសត្រូវបានជ្រើសរើសយកមកធ្វើការសម្ភាសដោយផ្តោតជាពិសេសទៅលើគ្រួសារដែលបានចូលរួមសកម្មភាពកសិកម្ម លើកលែងតែគ្រួសារដែលស្ថិតនៅក្នុងរាជធានីភ្នំពេញត្រូវបានដកចេញពីជំរឿនចំពោះភូមិដែលមានគ្រួសារកសិកម្មតិចជាង ៥គ្រួសារយោងទៅតាមទិន្នន័យជំរឿនប្រជាជនឆ្នាំ២០១៩។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ សំណាកគំរូសរុបចំនួន ១៥ ៤០៥ គ្រួសារកសិកម្មត្រូវបានសម្ភាសន៍ពេញលេញ។

បន្ថែមពីលើការអង្កេតគ្រួសារ កិច្ចការប្រមូលទិន្នន័យធ្វើដាច់ដោយឡែកសំដៅលើសហគ្រាសកសិកម្មធំៗ ដែលដំណើរការដោយសាជីវកម្ម សហគមន៍ និងស្ថាប័នរដ្ឋាភិបាល ឬឯកជន ដែលសំដៅដល់ការកាន់កាប់លក្ខណៈសហគ្រាសខ្នាតធំ នៅក្នុងវិស័យមិនមែនលក្ខណៈគ្រួសារ។ ការប្រមូលនេះត្រូវបានបង្កើតឡើងតាមរយៈជំរឿនមិនមែនលក្ខណៈគ្រួសារដែលគេស្គាល់ និងអាចចូលប្រើបាន។ ទោះជាយ៉ាងណា វាត្រូវបានទទួលស្គាល់ថាសហគ្រាសទាំងអស់មិនស្ថិតនៅក្នុងប្រទេសដែលអាចត្រូវបានរាប់បញ្ចូលនោះទេ ដោយសារតែបញ្ហាប្រឈមនៃដំណើរការ។ បញ្ជីនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំត្រូវបានចងក្រងពីអ្នកដែលត្រូវបានកំណត់នៅក្នុងកិច្ចការអង្កេត និងជំរឿនពីមុន រួមជាមួយនឹងការកាន់កាប់ថ្មីដែលត្រូវបានរាយការណ៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សរុបមក ទិន្នន័យត្រូវបានប្រមូលពីសហគ្រាសកសិកម្មខ្នាតធំចំនួន ៤៧៦ ដែលមានសារៈសំខាន់ជាងនៅក្នុងជុំមុន ដែលមានសហគ្រាសប្រហែល៣០០ ទៅ៤០០។

កម្រងសំណួរអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានធ្វើឡើងតាមរយៈការសម្ភាសន៍ផ្ទាល់ទល់មុខគ្នាដោយប្រើម៉ាស៊ីនកុំព្យូទ័រ ដែលបានបង្កើតជាកម្រងសំណួរជាភាសាអង់គ្លេស និងភាសាខ្មែរ និងបានចែករំលែកនៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ *(http://www.nis.gov.kh/index.php/km/)* គឺអាចទាញចេញពីកម្មវិធីនេះបាន។

ពេលវេលា និងរយៈពេលយោងនៃអង្កេត

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានធ្វើឡើងដោយផ្តោតទៅលើការកាន់កាប់កសិកម្មលក្ខណៈគ្រួសារ ហើយសកម្មភាពប្រមូលទិន្នន័យនៅក្នុងអំឡុងខែតុលា ដល់ខែវិច្ឆិកា ឆ្នាំ២០២៥។

រយៈពេលយោងនៃការអង្កេតគឺសួរក្នុង១២ខែកន្លងមក ដោយគិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ត្រូវបានកំណត់ជាកាលបរិច្ឆេទយោងសម្រាប់ការប្រមូលទិន្នន័យនេះ ប៉ុន្តែ

ទោះបីជាយ៉ាងណាក៏ដោយសូចនាករមួយចំនួនបានបញ្ចាក់ពេលវេលាជាក់លាក់ ដោយមិនបានប្រើកាលបរិច្ឆេទយោងទេ ហេតុដូច្នេះសម្រាប់ទិន្នន័យអំពីសូចនាកររនោះប្រើប្រាស់ទៅតាមការចាំបាច់។ ឧទាហរណ៍៖ ចំនួនបសុសត្វ បសុបក្សីដែលមាននៅថ្ងៃសម្ភាសន៍ ដោយគិតយកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ ជាកាលបរិច្ឆេទយោង។

តារាងបញ្ជីសំណាកគំរូ

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ សំណាកគំរូជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ (CAC ២០២៣) ត្រូវបានយកមកប្រើប្រាស់។ សំណាកនេះមានភូមិប្រមាណ ១៤ ៥០០ សម្រាប់ភូមិនីមួយៗ មានការប្រមូលយកព័ត៌មានដូចតទៅ៖ រាជធានី/ខេត្ត ក្រុង/ខណ្ឌ/ស្រុក ឃុំ/សង្កាត់ (ជនបទ/ទីប្រជុំជន) និងចំនួនគ្រួសារសរុប។ គោលដៅប្រជាជន គឺគ្រួសារដែលប្រកបរបរកសិកម្ម វារីវប្បកម្ម និង/ឬនេសាទ។ មានភូមិមួយចំនួននៅទីជនបទដែលស្ថិតនៅក្នុងក្រុង/ស្រុកទីប្រជុំជនមិនត្រូវបានរាប់បញ្ចូលក្នុងការជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣៖

- រាជធានីភ្នំពេញ ខណ្ឌចំការមន
- រាជធានីភ្នំពេញ ខណ្ឌដូនពេញ
- រាជធានីភ្នំពេញ ខណ្ឌ៧មករា
- រាជធានីភ្នំពេញ ខណ្ឌទួលគោក
- រាជធានីភ្នំពេញ ខណ្ឌមានជ័យ
- រាជធានីភ្នំពេញ ខណ្ឌសែនសុខ
- រាជធានីភ្នំពេញ ខណ្ឌឫស្សីកែវ
- រាជធានីភ្នំពេញ ខណ្ឌពោធិ៍សែនជ័យ
- រាជធានីភ្នំពេញ ខណ្ឌច្បារអំពៅ
- រាជធានីភ្នំពេញ ខណ្ឌជ្រោយចង្វារ
- រាជធានីភ្នំពេញ ខណ្ឌបឹងកេងកង

ការអង្កេតឆ្នាំមុនៗ សម្រាប់ការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ដើម្បីអនុវត្តតាមរយៈការជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ (CAC ២០២៣) បានកំណត់យកកម្រិតអប្បបរមាមួយ ដើម្បីកំណត់គ្រួសារដែលចូលរួមក្នុងសកម្មភាពកសិកម្ម។ ដោយគ្រួសារនីមួយៗនឹងត្រូវជ្រើសរើសសម្រាប់អង្កេត ប្រសិនបើគ្រួសារទាំងនោះដាំដំណាំលើផ្ទៃដីយ៉ាងហោចណាស់ ០,០៣ ហិកតា និង/ឬមានបសុសត្វធំចំនួន ២ និង/ឬ បសុសត្វតូចចំនួន ៣ និង/ឬ បសុបក្សីចំនួន ២៥ ក្បាលយ៉ាងតិច។ សម្រាប់ដំណើរការអង្កេតកសិកម្មកម្ពុជាប្រចាំឆ្នាំ គឺមិនបានកំណត់លើទំហំផ្ទៃដីអតិបរិមាទេ ចំនួនបសុសត្វ បសុបក្សីដែលមានចិញ្ចឹមមានចំនួនតិច ក៏ចាត់ជាគ្រួសារកសិកម្មផងដែរ ធ្វើដូចនេះដើម្បីផ្តល់ឱកាសដល់គ្រួសារកសិកម្មតូចៗត្រូវបានជ្រើសរើសជាសំណាកគំរូក្នុងអង្កេតនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយផ្អែកលើនីតិវិធី នៃការជ្រើសយកសំណាកត្រូវបានពន្យល់លម្អិតខាងក្រោម ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារដែលមានផ្ទៃដីធំ ឬចំនួនបសុសត្វ ឬបសុបក្សីច្រើនត្រូវបានកំណត់អត្តសញ្ញាណ និងបញ្ចូលក្នុងក្រុមសំណាកផ្សេងគ្នា ដើម្បីអាចជ្រើសយកបានគ្រួសារកសិកម្មទាំងនោះ។

វិធីសាស្ត្រជ្រើសរើសសំណាកគំរូ

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ប្រើប្រាស់វិធីសាស្ត្រជ្រើសរើសសំណាកគំរូពីរដំណាក់កាលគឺ ដំណាក់កាលទី១ ជ្រើសរើសយកភូមិ និងដំណាក់កាលទី២ ជ្រើសរើសយកគ្រួសារកសិកម្ម។ ភូមិជំរឿនចំនួន ១ ៣៥៥ ត្រូវបានជ្រើសរើសសម្រាប់ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ហើយភូមិអង្កេតនីមួយៗត្រូវបានជ្រើសយកចំនួន ១២ គ្រួសារកសិកម្ម សម្រាប់ធ្វើការសម្ភាសប្រមូលព័ត៌មានលម្អិត។ ដូច្នេះអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានជ្រើសរើសទំហំគ្រួសារសំណាកគំរូសរុបចំនួន ១៦ ២៦០ គ្រួសារ (គ្រួសារចំនួន១៨ ៩៥៨ ត្រូវបានរួមបន្ថែមអ្នកឆ្លើយតបក្នុងករណីកម្រិតខូចខាតនៃសំណាកគំរូពីជំរឿនកសិកម្មឆ្នាំ២០២៣ មានភាពកម្រិតខ្ពស់) សរុបចំនួន ១៥ ៤០៥ គ្រួសារកសិកម្មដែលត្រូវបានសម្ភាសន៍ដោយជោគជ័យ ភូមិអង្កេតចំនួន ១ ៣៥៥ ត្រូវបានបែងចែកទៅខេត្តជាដែនស្ថិតិ (Statistical Domains) តាមសមាមាត្រទៅនឹងចំនួនគ្រួសារនៅជនបទ។ តារាងទី១ខាងក្រោមបង្ហាញបំណែងចែកស្តីពីការជ្រើសរើសសំណាកគំរូសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥។ ភូមិជំរឿននៅក្នុងរាជធានី ខេត្ត ឈ្មោះភូមិទាំងអស់ត្រូវបានតម្រៀបតាមលំដាប់លេខកូដភូមិសាស្ត្រ ស្រុក ឃុំ និងដៅសម្គាល់ថា ភូមិស្ថិតនៅទីជនបទ-ទីប្រជុំជនបន្ទាប់មកធ្វើ ការជ្រើសរើសសំណាកជាលក្ខណៈប្រព័ន្ធចែដន្យតាមទំហំគ្រួសារដោយគិត សមាមាត្រប្រហាក់ប្រហែលគ្នា។

តារាងទី១.៦ ការបែងចែកសំណាកគំរូ

រាជធានី ខេត្ត	ចំនួនសរុបនៃគ្រួសារកសិកម្មពីជំរឿនកសិកម្ម ឆ្នាំ២០២៣	ចំនួនភូមិ ដែលបានជ្រើសរើសសំណាកគំរូ CAS ២០២៥	ចំនួនគ្រួសារកសិកម្មដែលបានសម្ភាសន៍ CAS ២០២៥
តំបន់វាលទំនាប	៧៣២ ៣១៤	៥៥០	៦ ៣៩១
ភ្នំពេញ	៦ ២៣៨	៤៥	៥៤០
ព្រៃវែង	១៧៧ ៩៤១	១៣១	១ ៥០៩
ស្វាយរៀង	១១០ ៩៩១	៥៩	៦៧៥
តាកែវ	១៥៣ ១៦២	៨៩	១ ០៤៦
ត្បូងឃ្មុំ	៩៤ ៣៩០	៧២	៨៤៨
កណ្តាល	៦៩ ៤០១	៧៨	៨៦៤
កំពង់ចាម	១២០ ១៩១	៧៦	៩០៩
តំបន់បឹងទន្លេសាប	៧០៧ ២៤០	៤៥០	៥ ១១៣

ប៉ៃលិន	១០ ១៨១	២៦	៣១០
បន្ទាយមានជ័យ	១២៧ ៦១៣	៦០	៦៩២
បាត់ដំបង	១២១ ៦២៩	៩៥	៩៨៤
ឧត្តរមានជ័យ	៣៣ ៩២១	២២	២៤២
សៀមរាប	១២៩ ៥៤៦	៧៤	៨៧១
កំពង់ឆ្នាំង	៩២ ៩៣៨	៥៦	៦៤៧
កំពង់ធំ	៩៦ ៨៨៤	៧២	៨៥០
ពោធិ៍សាត់	៩៤ ៥២៨	៤៥	៥១៧
តំបន់ឆ្នេរសមុទ្រ	១២៤ ១៥០	១៤១	១ ៦៤៧
កំពត	៩៩ ២៦៦	៨៤	៩៨៦
កែប	៥ ០៣៥	១៣	១៥៤
កោះកុង	១៣ ៨៨៣	២៦	២៩១
ព្រះសីហនុ	៥ ៩៦៦	១៨	២១៦
តំបន់ភ្នំ និងខ្ពង់រាប	២៨៦ ១០០	២១៤	២ ៤៧១
កំពង់ស្ពឺ	១១៨ ១៧០	៧៦	៨៨៥
ក្រចេះ	៥៣ ១៣៧	៣៩	៤៥៧
មណ្ឌលគិរី	១៤ ៦៧២	១៩	២១១
ព្រះវិហារ	៣៩ ៤៨៥	៣២	៣៧២
រតនគិរី	៣៦ ៣៦៣	២៩	៣៣៨
ស្ទឹងត្រែង	២៤ ២៧៣	១៩	២០៨
សរុប	១ ៨៤៩ ៨០៤	១ ៣៥៥	១៥ ៦២២

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

នីតិវិធីគណនាមេគុណ និងការប៉ាន់ស្មាន

នីតិវិធីនៃការជ្រើសរើសសំណាកគំរូ និងការចាត់ថ្នាក់ ដូចដែលបានរៀបរាប់លម្អិតខាងលើ បានបង្ហាញថាមានប្រូបាប៊ីលីតេនៃការជ្រើសរើសគ្រួសារកសិកម្មមានក្នុងកម្រិតខុសៗគ្នា។ ដោយពិចារណាចំណុចនេះ ការគណនាមេគុណត្រូវបានធ្វើឡើង សម្រាប់គ្រួសារកសិកម្មនីមួយៗនៅក្នុងសំណាក និងបានអនុវត្តន៍ចំពោះទិន្នន័យដែលបានរាយការណ៍សម្រាប់កំណត់ត្រានោះ។ មេគុណសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានកែតម្រូវសម្រាប់ករណីគ្មានចម្លើយ និងការខូចគុណភាព ហើយបានក្រិតតាមខ្នាតដោយប្រើចំនួនគ្រួសារកសិកម្មតាមខេត្ត ដែលទទួលបានតាមរយៈជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ (CAC 2023)។ ជាចុងក្រោយទិន្នន័យដែលបានរាយការណ៍នេះ ត្រូវបានបូកសរុបនៅកម្រិតខេត្ត តំបន់ និងថ្នាក់ជាតិ។

នីតិវិធីនៃការអង្កេត

ទិន្នន័យទាំងអស់នៅក្នុងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានប្រមូលទិន្នន័យតាមរយៈការបញ្ជូនមន្ត្រីសម្ភាសន៍ទៅសម្ភាសន៍ដោយផ្ទាល់ជាលក្ខណៈបុគ្គល ដោយប្រើកុំព្យូទ័រ (CAPI) ជាជំនួយ ដោយមានមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ និងមន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ជាអ្នកត្រួតពិនិត្យផ្ទាល់ ដោយទទួលបានការបណ្តុះបណ្តាលច្បាស់លាស់ ហើយអ្នកឆ្លើយតបសម្ភាសន៍ជាបុគ្គលពេញវ័យ មានចំណេះដឹងគ្រប់គ្រាន់អំពីសកម្មភាពកសិកម្មក្នុងកសិដ្ឋាន អ្នកឆ្លើយតបសម្ភាសន៍ជាម្ចាស់កសិដ្ឋានត្រូវបានផ្តល់អាទិភាពឱ្យចូលរួម។ ក្នុងករណីម្ចាស់កសិដ្ឋានអវត្តមានអាចសម្ភាសន៍ប្តី/ប្រពន្ធ ឬសមាជិកគ្រួសារ ដែលមានចំណេះដឹង អាចឆ្លើយតបសម្ភាសន៍បានផងដែរ។ មានការណែនាំថា ពុំត្រូវធ្វើសម្ភាសន៍ ឬសួរព័ត៌មានពីអ្នកជិតខាង ឬគ្រួសារផ្សេងទៀតឡើយ អំពីការកាន់កាប់កសិកម្មដែលកំពុងស្ថិតក្នុងការអង្កេតនេះ។

ទិន្នន័យក្នុងការអង្កេតនេះត្រូវបានសម្ភាសន៍ដោយប្រើប្រាស់កម្រងសំណួរគោល ដែលមានពន្យល់លម្អិតនៅក្នុងឯកសារសៀវភៅណែនាំមន្ត្រីសម្ភាសន៍នៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ដែលចែងពីទស្សនទាននិយមន័យ និងនីតិវិធីដែលត្រូវអនុវត្ត សម្រាប់ការប្រមូលទិន្នន័យ។ សេចក្តីព្រាងកម្រងសំណួរ និងឯកសារណែនាំ ត្រូវបានរៀបចំឡើងដោយផ្អែកលើអនុសាសន៍អំពីតម្រូវការទិន្នន័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគម្រោងគំនិតផ្តួចផ្តើម ៥០ x ២០៣០ ដើម្បីបំពេញកង្វះខាតទិន្នន័យកសិកម្ម។ កម្រងសំណួរ និងឯកសារណែនាំស្តីពីការប្រមូលទិន្នន័យនៃអង្កេតកសិកម្មកម្ពុជា ត្រូវបានកែសម្រួល ដោយផ្អែកលើបទពិសោធន៍ និងលទ្ធផលដែលទទួលបានក្នុងអំឡុងពេលសម្ភាសន៍សាកល្បងចំនួនពីរដង។ ឯកសារណែនាំមន្ត្រីសម្ភាសន៍នៃអង្កេតកសិកម្មកម្ពុជា ត្រូវបានបំពេញបន្ថែមដោយការត្រួតពិនិត្យលើភាពស៊ីសង្វាក់គ្នានៃទិន្នន័យ ដែលធ្វើឡើងពីចម្ងាយដោយក្រុមអ្នកគ្រប់គ្រងទិន្នន័យ និងនៅក្នុងដំណើរការផ្ទៀងផ្ទាត់ទិន្នន័យជាបន្តបន្ទាប់នៅពេលក្រោយមក។

ទិន្នន័យដែលប្រមូលបានទាំងអស់ ត្រូវបានរក្សាទុកនៅលើម៉ាស៊ីនមេ (Cloud) របស់ Amazon អ្នកគ្រប់គ្រងម៉ាស៊ីនមេ អាចទាញយកទិន្នន័យនេះក្នុងទម្រង់ផ្សេងៗ នៅពេលណាមួយក្នុងអំឡុងពេលប្រមូលទិន្នន័យ និងរហូតដល់ខែឧសភា ឆ្នាំ២០២៦ នៅពេលដែលម៉ាស៊ីនមេត្រូវបានបិទ។

យន្តការជំនួយក្នុងការសម្ភាស

មុននឹងចាប់ផ្តើមចុះសម្ភាសន៍ប្រមូលទិន្នន័យតាមមូលដ្ឋាន គម្រោងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានទទួលលិខិតអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចែកជូនដល់មន្ត្រីនៅមូលដ្ឋាន និងអ្នកតបសម្ភាសន៍ទៅតាមការចាំបាច់ ដើម្បីទទួលកិច្ចសហការពីគ្រប់គ្រួសារសម្ភាសន៍ និងសហគ្រាសកសិកម្មនានា ដែលធ្វើសកម្មភាពកសិកម្មនៅក្នុងប្រទេស។

ប្រតិបត្តិការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យទាំងអស់សម្រាប់អង្កេតកសិកម្មកម្ពុជាបានធ្វើឡើង ដោយមន្ត្រីសម្ភាសន៍ដែលបានទទួលការបណ្តុះបណ្តាលអំពីវិធីប្រមូលទិន្នន័យ ហើយមន្ត្រីសម្ភាសន៍ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីដែលមានសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើការសម្ភាសជម្រុះ។ ដោយសារអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ពាក់ព័ន្ធនឹងការប្រមូលទិន្នន័យពីការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ និងការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ការបណ្តុះបណ្តាលនេះត្រូវបានបែងចែក២វគ្គ គឺវគ្គទី១៖ បណ្តុះបណ្តាលគ្រូបង្គោល ដែលមានមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ និងត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ទាំងអស់ចូលរួម នៅទីស្តីការក្រសួងផែនការ និងវគ្គទី២៖ គឺការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ ដែលធ្វើឡើងនៅតាមរាជធានី ខេត្ត។ មន្ត្រីទាំងអស់ទទួលបានការបណ្តុះបណ្តាលដ៏ទូលំទូលាយអំពីទស្សនទាន និយមន័យ និងនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ។

មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពទិន្នន័យ។ សម្រាប់គម្រោងនេះទាំងមូលមាន អ្នកគ្រប់គ្រងទិន្នន័យចំនួន ៤៦នាក់ ដែលជាមន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិ។ មន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ មានភារៈទទួលខុសត្រូវក្នុងការជួយមន្ត្រីសម្ភាសន៍ ក្នុងការដោះស្រាយបញ្ហានៅតាមភូមិសាស្ត្រ លើកទឹកចិត្តឱ្យមានទំនាក់ទំនងល្អជាមួយបុគ្គលទាក់ទងនៅតាមភូមិ និងជំរុញកិច្ចសហប្រតិបត្តិការពីគ្រួសារកសិកម្មដែលជាអ្នកផ្តល់ចម្លើយ។ សម្រាប់គម្រោងនេះ មានមន្ត្រីត្រួតពិនិត្យនៅភូមិសម្ភាសន៍ចំនួន ៤៦នាក់ ក្នុងនោះ ២៤នាក់មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង២២ នាក់មកពីវិទ្យាស្ថានជាតិស្ថិតិ។ មន្ត្រីសម្ភាសន៍សរុបទាំងអស់មាន ៣៣៧នាក់ ក្នុងនោះ ១៩៧នាក់មកពីមន្ទីរផែនការរាជធានី ខេត្ត និង១៤០នាក់ជាមន្ត្រីមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តផងដែរ។ មន្ត្រីសរុបទាំងអស់មានចំនួន ៤២៩នាក់បានចូលរួមក្នុងការចុះប្រមូលទិន្នន័យ ប៉ុន្តែមានមន្ត្រីចំនួនច្រើនជាងនេះបានទទួលការបណ្តុះបណ្តាល ដោយមួយចំនួនត្រូវបានរក្សាទុកជាមន្ត្រីបម្រុងសម្រាប់គម្រោងកសិកម្មនេះ។ លើសពីនេះទៀត មន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិចំនួន ១១នាក់ នៅស្នាក់ការកណ្តាល (HQ) បានទទួលការបណ្តុះបណ្តាលអំពីការប្រើប្រាស់កម្មវិធី (Survey Solutions) ដើម្បីពិនិត្យ និងសម្រេចទទួលយកតារាងសំណួរចុងក្រោយពីមន្ត្រីសម្ភាសន៍។

លទ្ធផលនៃអង្កេតកសិកម្មកម្ពុជាប្រកបដោយគុណភាព គឺអាស្រ័យទៅលើដំណើរការ សម្ភាសន៍កត់ត្រាប្រមូលទិន្នន័យពីគ្រួសារកាន់កាប់កសិកម្ម។ ទោះបីជាការបណ្តុះបណ្តាលបានធ្វើឡើងយ៉ាងត្រឹមត្រូវ ហើយដំណើរការប្រមូលទិន្នន័យបានប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាពក៏ដោយ ប្រសិនបើក្នុងអំឡុងពេលដំណើរការប្រមូលទិន្នន័យ គ្មានការត្រួតពិនិត្យគុណភាពដោយប្រសិទ្ធភាពទេនោះ ទិន្នន័យចុងក្រោយនឹងនៅតែគ្មានគុណភាព។ អង្កេតកសិកម្មកម្ពុជា មានការត្រួតពិនិត្យ និងមធ្យោបាយទំនាក់ទំនងជាច្រើនកម្រិត ដូចដែល

បានចែងលម្អិតក្នុងឯកសារណែនាំមន្ត្រីសម្ភាសន៍នៃការអង្កេតកសិកម្មកម្ពុជា។ តួនាទីសម្រាប់ការត្រួតពិនិត្យ និងការទាក់ទង ត្រូវបានបង្កើតឡើងរួមជាមួយគោលការណ៍ណែនាំយ៉ាងទូលំទូលាយ ដែលរំលេចចេញនូវសកម្មភាពខុសៗគ្នា និងនីតិវិធីត្រួតពិនិត្យគុណភាព ដើម្បីតាមដានវឌ្ឍនភាពនៃការកត់ត្រាទិន្នន័យឱ្យបានត្រឹមត្រូវសម្រាប់អង្កេតកសិកម្មកម្ពុជា និងដើម្បីអាចរកឃើញបញ្ហាណាមួយភ្លាមៗនៅក្នុងពេលចុះប្រមូលទិន្នន័យ។ ការប្រើប្រាស់ CAPI សម្រាប់ប្រមូលទិន្នន័យ អាចមានភាពងាយស្រួលក្នុងការត្រួតពិនិត្យទិន្នន័យទាន់ពេលវេលានូវលំហូរ និងគុណភាពទិន្នន័យ។

ការកែច្នៃទិន្នន័យ

បន្ទាប់ពីការសម្ភាសគ្រួសារកសិកម្មបានបញ្ចប់ មន្ត្រីសម្ភាសន៍ត្រូវបញ្ជូនកម្រងសំណួរដែលបានបំពេញរួចតាមកម្មវិធី Survey Solutions ទៅកាន់មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ ដោយមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ប្រសិនបើរកឃើញកំហុស ឬទិន្នន័យដែលគួរសង្ស័យ មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យនឹងបញ្ជូនកម្រងសំណួរត្រឡប់ទៅឱ្យមន្ត្រីសម្ភាសន៍វិញ ដោយសរសេរមូលហេតុបញ្ជាក់ ដើម្បីសម្ភាសន៍ឡើងវិញជាមួយអ្នកតបសម្ភាសន៍តាមការចាំបាច់ ហើយបញ្ជូនមកមន្ត្រីត្រួតពិនិត្យគុណភាពវិញ។ នៅពេលមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យបានផ្ទៀងផ្ទាត់តារាងសំណួរត្រឹមត្រូវ ហើយសម្រេចបញ្ជូនតារាងសំណួរទៅឱ្យមន្ត្រីស្នាក់ការកណ្តាលជាអ្នកសម្រេចចុងក្រោយ។

ប្រសិនបើក្នុងអំឡុងពេលត្រួតពិនិត្យនេះ មន្ត្រីនៅទីស្នាក់ការកណ្តាលរកឃើញមានកំហុសណាមួយ ឬទិន្នន័យគួរឱ្យសង្ស័យ តារាងសំណួរនោះអាចត្រូវបញ្ជូនទៅមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ រួចបញ្ជូនបន្តទៅមន្ត្រីសម្ភាសន៍វិញ ដើម្បីធ្វើការផ្ទៀងផ្ទាត់ ឬកែតម្រូវតាមការចាំបាច់។

ការសម្អាតទិន្នន័យ និងការគណនាតួលេខប៉ាន់ប្រមាណក្នុងការអង្កេតនេះ ត្រូវបានធ្វើឡើងដោយប្រើកម្មវិធី RStudio ការពិនិត្យភាពត្រឹមត្រូវនៃទិន្នន័យត្រូវបានកំណត់ចាប់តាំងពីពេលដែលការបង្កើតកម្រងសំណួរនៅក្នុង (CAPI) មកម្លេះ ដោយសារកម្មវិធី Survey Solutions អាចឱ្យមានការត្រួតពិនិត្យភាពស៊ីសង្វាក់គ្នានៅក្នុងប្រព័ន្ធប្រមូលទិន្នន័យ។ បន្ទាប់ពីតារាងសំណួរត្រូវបានបញ្ចប់រួចរាល់ ការសម្អាតទិន្នន័យត្រូវបានចាប់ផ្តើមភ្លាមៗ មានការកំណត់ភាពមិនប្រក្រតីនៃទិន្នន័យដោយយោងទៅតាមការប្រៀបធៀបទិន្នន័យជំរឿនមុនៗ ការកំណត់តម្លៃ ឬបរិមាណដែលអាចទទួលយកបានជាអតិបរមា និងអប្បបរមាសម្រាប់ធាតុផលិតកម្មកសិកម្ម ហើយបានធ្វើការផ្ទៀងផ្ទាត់នូវភាពមិនប្រក្រតីនោះ ដោយសួរត្រឡប់ទៅអ្នកឆ្លើយតបសម្ភាសន៍ និង/ឬមន្ត្រីសម្ភាសន៍។ លើសពីនេះ បន្ទាប់ពីសម្អាតទិន្នន័យរួចរាល់ មានការអនុវត្តជំហានមួយទៀតគឺ ការសន្មត់ទិន្នន័យ ការងារនេះត្រូវបានធ្វើឡើងដើម្បីសន្មត់តួលេខដែលបាត់ដោយសារគ្មានចម្លើយក្នុងពេលសម្ភាសន៍។

ស្តង់ដារនៃការបោះពុម្ពផ្សាយ

ក្នុងការរៀបចំការបោះពុម្ពជារបាយការណ៍ចុងក្រោយនេះ មានការបង្កើតស្តង់ដារសម្រាប់ការរៀបចំតារាងទិន្នន័យ Excel online on the NIS website *(http://www.nis.gov.kh/index.php/km/)* ស្តង់ដារទាំងនេះមានដូចជា៖

- តួលេខទាំងអស់ដែលទាក់ទងនឹងចំនួនគ្រួសារ ត្រូវបានបង្គត់ទៅរកលេខជិតបំផុតគិតជាពាន់

- ភាគរយដែលបានគណនាតែងតែផ្អែកលើទិន្នន័យដើមទោះជាយ៉ាងនេះដោយសារការបង្គត់លេខតារាងមួយចំនួនដែលមានតួលេខជាភាគរយអាចមានផលបូកសរុបមិនស្មើ ១០០ ភាគរយ
- នៅក្នុងប្រអប់ទទេមិនមានតួលេខមានន័យថាចំនួនគ្រួសារមានតិចជាង ១០០០ ឬមានកម្រិតមេគុណលំអៀងខ្ពស់ (CV) ចាប់ពី ៣៥ ភាគរយ ឡើងទៅ ហើយគេអាចរកឃើញអ្នកឆ្លើយសំណួរទាំងអស់នោះបានយ៉ាងងាយស្រួល ប៉ុន្តែបើមានលក្ខខណ្ឌណាមួយក្នុងចំណោមពីរខាងលើត្រូវបានបង្ហាញនោះតារាងតួលេខនឹងទទេមិនមានទិន្នន័យឡើយ។

ស្តង់ដារខាងលើធ្វើឱ្យមានដែនកំណត់នៃការចេញផ្សាយទិន្នន័យមានគុណភាពទាប ដោយសារតែ តួលេខនៅក្នុងខេត្ត ឬតំបន់មានចំនួនតិចយោងទៅតាមស្តង់ដាររាយការណ៍របស់វិទ្យាស្ថានជាតិស្ថិតិ។

ដែនកំណត់នៃការអង្កេតកសិកម្មកម្ពុជា

នៅក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ក៏ដូចការធ្វើអង្កេតសំណាកគំរូផ្សេងៗផងដែរ គឺតែងតែមានដែនកំណត់ចំពោះទិន្នន័យដែលផលិត និងដែនកំណត់នៃការបកស្រាយមិនអាចធ្វើការប្រៀបធៀបជាមួយប្រភពទិន្នន័យផ្សេងបាន។ ចំពោះអ្នកអាន ឬអ្នកប្រើប្រាស់ទិន្នន័យដែលមាននៅក្នុងរបាយការណ៍នេះត្រូវពិចារណាជាសំខាន់ចំពោះដែនកំណត់ដូចខាងក្រោម៖

- ទិន្នន័យស្វ័យរាយការណ៍៖ អ្នកផ្តល់ចម្លើយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានស្នើសុំឱ្យផ្តល់ព័ត៌មានអំពីការកាន់កាប់កសិកម្មនោះ។ ព័ត៌មានទាំងនេះអាចទទួលផលប៉ះពាល់ពីការចងចាំរបស់អ្នកផ្តល់ចម្លើយក្នុងអំឡុងពេលយោងលើប្រភេទសំណួរជាច្រើនក្នុងកម្រងសំណួរ ដោយផ្តោតក្នុងរយៈពេល១២ខែកន្លងមក ។
- រយៈពេលចងចាំរបស់អ្នកតបសម្ភាសន៍៖ ទិន្នន័យស្វ័យរាយការណ៍ក៏អាចរងការប៉ះពាល់បន្ថែមក្នុងអំឡុងពេលយោងដោយផ្ទាល់ និងអំឡុងពេលប្រមូលទិន្នន័យផងដែរ ដោយសារពេលវេលាមានការយឺតយ៉ាវ ទើបការប្រមូលទិន្នន័យមានការពន្យាពេលច្រើនខែឆ្ងាយពីអំឡុងពេលយោង។
- កម្រងសំណួរ និងនីតិវិធីសម្ភាសន៍៖ នៅក្នុងអង្កេតកសិកម្មកម្ពុជាត្រូវបានប្រឹងប្រែងតាមការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យជាប្រព័ន្ធស៊ីសង្វាក់គ្នា ក្នុងដំណើរការប្រមូលទិន្នន័យនេះ។ ការបណ្តុះបណ្តាលលើខ្លឹមសារសំណួរនីមួយៗ ដល់មន្ត្រីសម្ភាសន៍ គឺត្រូវបានប្រើប្រាស់ស្តង់ដារដូចៗគ្នានៅទូទាំងប្រទេស ប៉ុន្តែជាលក្ខណៈបុគ្គលរបស់មន្ត្រីសម្ភាសន៍ អាចធ្វើឱ្យចាកឆ្ងាយពីខ្លឹមសារនៃសំណួរអាចប៉ះពាល់ដល់ការឆ្លើយតបសំណួរ និងជះឥទ្ធិពលដល់លទ្ធផលចុងក្រោយនៃការអង្កេតនេះ។

ដូចដែលមើលឃើញនៅក្នុងរបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ ស្រាប់ជាលទ្ធផល ដែលបានចេញផ្សាយផ្តោតលើទិន្នន័យកម្រិតជាតិ និងតំបន់/តំបន់តែប៉ុណ្ណោះ មិនបានលម្អិតដល់ថ្នាក់ក្រោមជាតិទេ ព្រោះទិន្នន័យមានដែនកំណត់ និងដើម្បីកាត់បន្ថយពេលវេលាក្នុងការសរសេររបាយការណ៍ ប៉ុន្តែទិន្នន័យកម្រិតថ្នាក់ក្រោមជាតិទាំងអស់ នឹងត្រូវបានផ្តល់ជូននៅក្នុងឯកសារទិន្នន័យលម្អិតដែលមានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ផ្នែកទី២: ផលិតកម្មដំណាំ













Food and Agriculture Organization of the United Nations

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

សហការជាមួយ


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

ផ្នែកទី២ ផ្ទៃដីកសិកម្ម និងផលិតកម្មដំណាំ


ប្រទេសកម្ពុជាមានផ្ទៃដីកសិកម្មសរុបប្រមាណ ៤ ៤២១ ០០០ ហិកតា សម្រាប់គ្រួសារកសិកម្ម។ តំបន់ដែលមានផ្ទៃដីកសិកម្មធំជាងគេបំផុតគឺ តំបន់បឹងទន្លេសាប មានប្រមាណ ២ ២១៦ ០០០ហិកតា តំបន់វាលទំនាប មានប្រមាណ ១ ០៥៦ ០០០ហិកតា តំបន់ភ្នំ និងខ្ពង់រាប មានប្រមាណ ១ ០១៤ ០០០ហិកតា ហើយតំបន់ឆ្នេរសមុទ្រ មានផ្ទៃដីកសិកម្មតិចជាងគេបំផុតប្រមាណ ១៣៦ ០០០ហិកតា ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

គ្រួសារកសិកម្ម ភាគច្រើនមានការកាន់កាប់ផ្ទៃដីទំហំតូច។ ចំពោះគ្រួសារកាន់កាប់កសិកម្មដែលមានដីធ្វើកសិកម្មតិចជាង១ហិកតា មានចំនួនប្រមាណ ៤៣% នៃចំនួនគ្រួសារកសិកម្មសរុប ហើយទំហំជាមធ្យមនៃដីធ្វើកសិកម្មនៅទូទាំងប្រទេសកម្ពុជាគឺមាន ២,៤ហិកតា ក្នុងមួយគ្រួសារ។ នៅតំបន់ឆ្នេរសមុទ្រ គ្រួសារកសិកម្មមានទំហំដីធ្វើកសិកម្មតិចជាងគេបង្អស់ជាមធ្យមប្រមាណ ១,១ហិកតា ក្នុងមួយគ្រួសារ។ ចំណែកឯនៅតំបន់បឹងទន្លេសាប និងតំបន់ភ្នំនិងខ្ពង់រាប គ្រួសារកសិកម្មមានដីធ្វើកសិកម្មធំជាងគេ ជាមធ្យមមានប្រមាណ ៣,០ ហិកតា និង ៣,៤ ហិកតា ក្នុងមួយគ្រួសារតាមលំដាប់លំដោយ។


រូបទី ២.១. ផ្ទៃដីកសិកម្មសរុប តាមប្រភេទទំហំ និងតំបន់ ឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ទោះបីជាដីកសិកម្មអាចត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពច្រើនយ៉ាងក៏ដោយ ផលិតកម្មដំណាំរយៈពេលខ្លី គឺជាការប្រើប្រាស់ដីចម្បងជាងគេនៅក្នុងប្រទេសកម្ពុជា។ ផ្ទៃដីកសិកម្មប្រហែល ៣,២លានហិកតា ត្រូវបានប្រើប្រាស់សម្រាប់ផលិតកម្មដំណាំរយៈពេលខ្លី។ ក្នុងការប្រៀបធៀប ការដាំដំណាំរយៈពេលវែង ដែលជាការប្រើប្រាស់ដីធំជាងគេទីពីរ គឺប្រហែល ២៨.៣% ដែលមានផ្ទៃដីប្រើប្រាស់ចំនួន ៩១៩ ៨៨២ ហិកតា។ ដីទំនេរបណ្តោះអាសន្ន ជាការប្រើប្រាស់ដីធំជាងគេទីបី មានប្រមាណតែ ១១៨ ០០០ហិកតាប៉ុណ្ណោះក្នុងការប្រៀបធៀប។


រូបទី ២.២. ផ្ទៃដីកសិកម្ម តាមចំណាត់ថ្នាក់ នៅប្រទេសកម្ពុជា ឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ទំហំក្បាលដីកសិកម្មដែលបានទទួលពីកេរមរតក មានចំនួន ១,២ លានក្បាលដី។ ទំហំក្បាលដីដែលបានទិញ មានចំនួន ២៤៣ ០០០ក្បាលដី។ គ្រួសារកសិកម្មកាន់កាប់ក្បាលដីដោយគ្មានការអនុញ្ញាតមានចំនួន ១២ ០០០ ទោះបីមានការលំអៀងរបស់អ្នកឆ្លើយតបដែលបានរាយការណ៍តិចតួចក៏ដោយ។

រូបទី ២.៣ ប្រភពនៃការកាន់កាប់ក្បាលដីតាមគ្រួសារកសិកម្មនៅកម្ពុជា ឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ផលិតកម្មដំណាំ


សកម្មភាពចម្បង នៃគ្រួសារកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជា គឺការដាំដុះ និងការប្រមូលផលដំណាំរយៈពេលខ្លី និងដំណាំរយៈពេលវែង។ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១,៨៨លាន បានរាយការណ៍ថា បានចូលរួមដាំដំណាំចំនួន ១,៧៦លានគ្រួសារ ។

ដំណាំរយៈពេលខ្លី គឺជាដំណាំដែលមានវដ្តលូតលាស់តិចជាងមួយឆ្នាំ ហើយក្រោយពេលប្រមូលផលត្រូវបានសាបព្រោះឡើងវិញ ឬដាំឡើងវិញសម្រាប់វដ្តផលិតកម្មផ្សេងទៀត។ ដំណាំរយៈពេលខ្លី ដែលបង្ហាញក្នុងការអង្កេតកសិកម្មកម្ពុជា គឺជាដំណាំដែលដាំដុះតាមរដូវកាលក្នុងអំឡុងពេលឆ្នាំយោង។ ដំណាំរយៈពេលវែង គឺជាដំណាំដែលមានវដ្តលូតលាស់លើសពីមួយឆ្នាំដែលកំពុងដាំដុះ។

ដោយសារប្រភេទដំណាំជាច្រើនដែលដាំដុះនៅប្រទេសកម្ពុជា និងកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយបន្ទុកលើអ្នកឆ្លើយតប និងរយៈពេលសម្ភាសន៍ ដូច្នេះទិន្នន័យលម្អិតត្រូវបានប្រមូលសម្រាប់តែដំណាំសំខាន់ជាងគេ ៤២ មុខប៉ុណ្ណោះនៅប្រទេសកម្ពុជា ដែលត្រូវបានកំណត់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សម្រាប់ដំណាំសំខាន់ទាំង ៤២ មុខនេះ អ្នកតបសម្ភាសន៍ បានផ្តល់ព័ត៌មានដែលទាក់ទងនឹងផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល បរិមាណផលប្រមូលបាន ការប្រើប្រាស់ជី ការប្រើប្រាស់ថ្នាំកសិកម្ម ការប្រើប្រាស់ប្រព័ន្ធស្រោចស្រព និងគោលបំណងចំបងនៃផលិតកម្មដំណាំ សម្រាប់លក់ ឬ សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ដើម្បីកាត់បន្ថយបន្ទុកលើអ្នកឆ្លើយតបសម្ភាសន៍ ទិន្នន័យសម្រាប់ដំណាំរយៈពេលវែង ត្រូវបានប្រមូល ផ្ទៃដីគិតជាហិកតា ឬជាចំនួនដើមដែលបានដាំដោយផ្អែកលើចម្លើយរបស់អ្នកតបសម្ភាសន៍។ ដូចនេះទិន្នន័យដែលបានរាយការណ៍ពីចំនួនដើមដែលបានដាំ ត្រូវបានបំលែងទៅជាហិកតា ដោយផ្អែកលើមេគុណបំលែងដែលបានផ្តល់ឱ្យដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ឧបសម្ព័ន្ធ ១) ។

ប្រការសំខាន់ គឺអ្នកប្រើប្រាស់ទិន្នន័យត្រូវកត់សម្គាល់ថា នីតិវិធីដែលបានប្រើនៅក្នុងអង្កេតកសិកម្មឆ្នាំ២០២៥ ខុសប្លែកពីនីតិវិធីដែលបានប្រើនៅក្នុងកិច្ចការវាយតម្លៃកសិកម្មផ្សេងទៀត នៅប្រទេសកម្ពុជា។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ គឺជាការជ្រើសរើសសំណាកគំរូដោយចៃដន្យ តាមនីតិវិធីទិន្នន័យដែលបានរាយការណ៍ ក្នុងការកាន់កាប់កសិកម្មរយៈពេលឆ្នាំយោងជាក់លាក់ គឺចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ហើយបានគ្របដណ្តប់គ្រប់កម្រិត ទាំងកម្រិតគ្រួសារកសិកម្ម និងសហគ្រាសកសិកម្មខ្នាតធំ ។ ជាលទ្ធផល ចំនួនផ្ទៃដីសរុប បរិមាណផលិតផល និងទិន្នផល ដែលបានគណនាសម្រាប់ដំណាំនានា អាចខុសគ្នាពីប្រភពទិន្នន័យផ្សេងទៀត ។

រូបទី ២.៤ បានបង្ហាញពីការដាំដំណាំ១០មុខសំខាន់មាន៖ ស្រូវធម្មតា ដូង ចេក ស្វាយ ស្រូវក្រអូប ស្វាយចន្ទី ដំឡូងមី ខ្នុរ ក្រូចឆ្មា និងផ្លែទៀប។ គ្រួសារកាន់កាប់កសិកម្មចំនួន ១,១៩លាន បានរាយការណ៍ថាបានដាំស្រូវធម្មតា ហើយការដាំដំណាំធំទីពីរមានគ្រួសារកសិកម្មចំនួន ៥៤៦ ០០០ បានដាំដំណាំដូង និង ៥៤៥ ០០០ ដំណាំចេករៀងគ្នា។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ដំណាក់រយៈពេលខ្លី


គ្រាប់ធញ្ញជាតិ

ដំណាំសំខាន់ៗចំនួន២មុខ ដែលដាំដោយគ្រួសារកសិកម្មនៅប្រទេសកម្ពុជាគឺ ស្រូវ និងពោត។ ពូជស្រូវដែលដាំ មានដូចជា ស្រូវធម្មតា ស្រូវក្រអូប និងស្រូវដំណើប។ ពោត ត្រូវបានចាត់ជាពូជពោត សលឿង និងស្វាយ ។

ក្នុងចំណោមស្រូវទាំង៣ប្រភេទ មានការដាំពូជស្រូវធម្មតាទូទៅច្រើនជាងគេ លើផ្ទៃដីដាំដុះ មានប្រមាណ ២,៥០ លានហិកតា និងផ្ទៃដីប្រមូលផលមានប្រមាណ ២,៤៩ លានហិកតា។ ទិន្នផលស្រូវធម្មតាត្រូវបានប៉ាន់ប្រមាណថាទទួលបានជាមធ្យម ៣ ៣៣០ គីឡូក្រាមក្នុង១ហិកតា ដោយបរិមាណផលសរុបដែលប្រមូលបាននៅប្រទេសកម្ពុជាមានប្រមាណ ៨,៣០ លានតោន នៃស្រូវធម្មតា។ តំបន់បឹងទន្លេសាប ជាតំបន់ដែលបានដាំដុះស្រូវធម្មតាច្រើនជាងគេ លើទំហំផ្ទៃដី ១,៣១ លានហិកតា ចំណែកតំបន់វាលទំនាបមានដំណាំស្រូវលើផ្ទៃដីទំហំ ៨៣៥ ០០០ហិកតា តំបន់ភ្នំ និងខ្ពង់រាប មានដំណាំស្រូវលើផ្ទៃដីទំហំ ២៨៧ ០០០ ហិកតា និងតំបន់ឆ្នេរសមុទ្រ មានដំណាំស្រូវលើផ្ទៃដីទំហំ ៧៣ ០០០ហិកតា។




ប្រភព: អង្គេតកសិកម្មកម្ពុជាឆ្នាំ២០២៥




ប្រភព: អង្គេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ពូជស្រូវក្រអូប ត្រូវបានដាំលើផ្ទៃដីប្រមាណ ៦៥៥ ០០០ហិកតា នៅប្រទេសកម្ពុជា ដោយមានផ្ទៃដីប្រមូលផលទំហំប្រមាណ ៦៥១ ០០០ ហិកតា។ ទិន្នផលជាមធ្យមក្នុងមួយហិកតា នៃពូជស្រូវក្រអូបមានប្រមាណ ២ ៥១៨ គីឡូក្រាមក្នុង១ហិកតា ហើយមានបរិមាណផលសរុប ដែលប្រមូលបានប្រមាណ ១,៦៤ លានតោន ខុសពីពូជស្រូវធម្មតា ផលិតកម្មស្រូវក្រអូបភាគច្រើនត្រូវបានប្រមូលផលនៅតំបន់បឹងទន្លេសាប ដែលមានផ្ទៃដីដាំដុះប្រមាណ ៤១៣ ០០០ហិកតា។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


ដំណាំពោត ត្រូវបានដាំដុះដោយគ្រួសារកសិកម្មលើផ្ទៃដីប្រមាណ ៨៦ ០០០ហិកតា នៅប្រទេសកម្ពុជា ចំណែកតំបន់បឹងទន្លេសាប មានផ្ទៃដីដុះខ្ពស់ជាងគេប្រមាណ ៧៩ ០០០ ហិកតា ។ ទិន្នផលជាមធ្យមមានប្រមាណ ៦ ៥១៥ គីឡូក្រាមក្នុង១ហិកតា ដោយបរិមាណផលសរុបដែលប្រមូលបាន មានប្រមាណ ៥៤៩ ០០០ តោន នៅប្រទេសកម្ពុជា ។

ដំណាំយកមើម

ដំណាំយកមើមដែលបានដាំដោយគ្រួសារកសិកម្ម មានដូចជា ដំឡូងមី ដំឡូងផ្ទាំ ត្រាវ សាគូ និងប៊ិគក់។ ផ្ទៃដីដាំដំឡូងមីមានទំហំផ្ទៃដីច្រើនជាងគេរហូតដល់ ៤២១ ០០០ហិកតា និងផ្ទៃដីប្រមូលផល ៤១៦ ០០០ ហិកតា។ ទិន្នផលដំឡូងមីជាមធ្យមទទួលបានប្រមាណ ១៣ ៤១០ គីឡូក្រាមក្នុងមួយហិកតា ជាមួយនឹង បរិមាណផលសរុបទូទាំងប្រទេសកម្ពុជា មានចំនួនប្រមាណ ៥,៥៦ លានតោន។



ប្រភព: អង្គេតកសិកម្មកម្ពុជាឆ្នាំ២០២៥




ប្រភព: អង្គេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ដំណាំសម្រាប់គ្រឿងទេស គ្រឿងក្រអូប និង រុក្ខជាតិឱសថ

ការអង្កេតនេះ ក៏បានប្រមូលព័ត៌មានអំពីដំណាំគ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថ ដូចជា ស្លឹកគ្រៃ រមៀត ជីអង្កាម និងស្លឹកម្លូ។ គ្រួសារកសិកម្ម បានរាយការណ៍ពីការដាំស្លឹកគ្រៃ មានចំនួន ៧៥ ០០០ គ្រួសារ ហើយគ្រួសារដាំរមៀត មានចំនួន ៨ ០០០គ្រួសារ ដាំម្លូមានចំនួន ២ ៥០០ គ្រួសារ និងគ្រួសារដាំជីអង្កាមមានចំនួនប្រហែល ២ ៤០០គ្រួសារ។

ដំណាំឧស្សាហកម្ម

ដំណាំឧស្សាហកម្ម នៅក្នុងការអង្កេតនេះ គឺដំណាំអំពៅ។ គ្រួសារកសិកម្មដាំអំពៅសរុបនៅប្រទេសកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមាន ១៨ ០០០ គ្រួសារ ដែលក្នុងនោះគ្រួសារកសិកម្មនៅតំបន់បឹងទន្លេសាប ចំនួន ៩ ០០០គ្រួសារ និងតំបន់វាលទំនាប មានប្រមាណ ៦ ០០០គ្រួសារបានដាំដំណាំអំពៅ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ដំណាំបន្លែ

បន្លែជាច្រើនប្រភេទត្រូវបានដាំដុះនៅទូទាំងប្រទេស រួមទាំងបន្លែស្លឹក ឬដើម។ បន្លែផ្លែ ឫស មើម បន្លែបៃតង។ល។ បន្លែស្លឹក ឬដើមរួមមាន ស្លឹកខ្ចឹម ស្ពៃខ្មៅ ស្ពៃក្រញាញ់ ស្ពៃស និងត្រកួន។ ការអង្កេតនេះមានព័ត៌មានពីបន្លែផ្លែ ដូចជាម្ទេស ត្រសក់ ត្រប់ នានោង ល្ពៅ ផ្លែឪឡឹក និងត្រឡាច។ បន្លែបៃតង រួមមានសណ្តែកកួរ បន្លែផ្សេងទៀតរួមមានផ្កាខាត់ណាខៀវ។

គ្រួសារកសិកម្មប្រមាណ ២៣ ០០០ គ្រួសារ បានរាយការណ៍ថាបានដាំត្រកួន។ ចំនួនគ្រួសារដែលបានរាយការណ៍ថាដាំត្រសក់មានប្រមាណ ១៥ ០០០គ្រួសារ នៅប្រទេសកម្ពុជា ជាមួយទំហំផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលប្រមាណ ៤ ៦០០ ហិកតា ។ ទិន្នផលសរុបនៃត្រសក់ប្រមាណ ៣៣ ០០០ តោន។ គ្រួសារកសិកម្មប្រមាណ ៩ ០០០ គ្រួសារ បានរាយការណ៍ថាបានដាំល្ពៅនៅកម្ពុជា និងគ្រួសារកសិកម្មប្រមាណ ៧ ០០០ គ្រួសារ បានរាយការណ៍ថាបានដាំត្រប់ ហើយទិន្នផលជាមធ្យមទទួលបាន ៩ ១២៧ គីឡូក្រាម ក្នុង ១ហិកតា និងគ្រួសារកសិកម្មបានដាំឪឡឹកមានប្រមាណ ៤ ០០០ គ្រួសារ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


ដំណាក់រយៈពេលវែង

ដំណាំហូបផ្លែ

ដំណាំពពួកក្រូច ជាដំណាំដែលត្រូវបានរកឃើញថាបានដាំដុះច្រើនជាងគេនៅប្រទេសកម្ពុជា ហើយដំណាំដែលស្ថិតក្នុងការអង្កេតកសិកម្មនេះ មានដូចជា ក្រូចថ្លុង ក្រូចឆ្មា និងក្រូចពោធិ៍សាត់។ គ្រួសារ កសិកម្មប្រមាណ ៣១ ០០០ គ្រួសារក្នុងប្រទេសកម្ពុជា បានដាំក្រូចពោធិ៍សាត់ លើផ្ទៃដីទំហំសរុបប្រមាណ ២ ៣០០ ហិកតា ដោយទិន្នផលជាមធ្យមទទួលបាន ៣ ០០០ គីឡូក្រាមក្នុង១ហិកតា។

ប្រភេទដំណាំហូបផ្លែ ដែលបានដាំដុះច្រើនជាងនៅប្រទេសកម្ពុជា រួមមាន ចេក ស្វាយ ខ្នុរ ល្ហុង ត្របែក ទៀប ទឹកដោះគោ ទុរេន មៀន និងដំណាំហូបផ្លែផ្សេងទៀត។


រូបទី ២.១០ ចំនួនគ្រួសារកសិកម្មដាំដំណាំផ្លែឈើតាមប្រភេទដំណាំនៅកម្ពុជា ឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

គ្រួសារកសិកម្មប្រមាណ ៤៦៥ ០០០ គ្រួសារក្នុងប្រទេសកម្ពុជា បានដាំស្វាយ លើផ្ទៃដីទំហំសរុបប្រមាណ ៥២ ០០០ ហិកតា ហើយផ្ទៃដីប្រមូលផលសរុបប្រមាណ ៤៨ ០០០ហិកតា គឺជាផ្ទៃដីដាំស្វាយដែលជាដំណាំធំ ទីពីរនៅប្រទេសកម្ពុជា។ ទិន្នផលគិតជាមធ្យមទទួលបាន ៦ ១៥៩ គីឡូក្រាមក្នុង១ហិកតាសម្រាប់ដំណាំស្វាយ។ បើគិតតាមតំបន់ គ្រួសារកសិកម្មប្រមាណ ១៨៣ ០០០ បានដាំដំណាំស្វាយ នៅតំបន់វាលទំនាបតាមពីក្រោយដោយតំបន់បឹងទន្លេសាប មានគ្រួសារប្រមាណ ១៦៩ ០០០ បានដាំដំណាំស្វាយ និងតំបន់ដែលមានគ្រួសារដាំដំណាំស្វាយតិចជាងគេ គឺតំបន់ឆ្នេរសមុទ្រមានប្រមាណ ៤៨ ០០០គ្រួសារ។

រូបទី ២.១១ ចំនួនគ្រួសារដាំដំណាំស្វាយតាមតំបន់ ឆ្នាំ២០២៥




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

គ្រួសារកសិកម្មប្រមាណ ៥៤៥ ០០០ គ្រួសារ ក្នុងប្រទេសកម្ពុជា បានដាំដំណាំចេក លើផ្ទៃដីទំហំសរុបប្រមាណ ១២ ០០០ ហិកតា ហើយផ្ទៃដីប្រមូលផលសរុបប្រមាណ ៦ ០០០ ហិកតា។ បរិមាណផលសរុបប្រមាណ ៦៣ ៧០០ តោន ដោយទិន្នផលគិតជាមធ្យមទទួលបាន ១០ ៥០០ គីឡូក្រាមក្នុង១ហិកតា។ តំបន់បឹងទន្លេសាប ជាតំបន់ដែលដាំចេកច្រើនជាងគេបំផុត បានរាយការណ៍ថាមានច្រើនជាង ៤ ២០០ ហិកតា។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


គ្រួសារកសិកម្មមានប្រមាណ ១៦៩ ០០០ គ្រួសារ ក្នុងប្រទេសកម្ពុជា បានដាំខ្នុរ លើផ្ទៃដីទំហំសរុបប្រមាណ ៣ ០០០ ហិកតា ហើយផ្ទៃដីប្រមូលផលសរុបប្រមាណ ១ ៣០០ ហិកតា។ ទិន្នផលគិតជាមធ្យមទទួលបាន ៦ ៥៧៩ គីឡូក្រាមក្នុង១ហិកតា។ គ្រួសារកាន់កាប់កសិកម្មប្រមាណ ៨៣ ០០០គ្រួសារ នៅតំបន់វាលទំនាប បានរាយការណ៍ថាបានដាំខ្នុរច្រើនជាងគេ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ស្វាយចន្ទី


ក្នុងចំណោមរុក្ខជាតិដែលផ្តល់គ្រាប់សម្រាប់បរិភោគ ការអង្កេតកសិកម្មនេះ បានប្រមូលទិន្នន័យអំពីដំណាំស្លា និងស្វាយចន្ទី ក្នុងនោះគ្រាប់ស្វាយចន្ទីមានការពេញនិយមជាងគេ។ គ្រួសារកសិកម្មប្រមាណ ២០២ ០០០គ្រួសារ នៅប្រទេសកម្ពុជា បានដាំស្វាយចន្ទី លើទំហំផ្ទៃដី សរុបប្រមាណ ៥៨០ ០០០ ហិកតា ដោយផ្ទៃដីប្រមូលផល ៥១១ ០០០ ហិកតា និងបរិមាណផលប្រមាណ ៦២១ ៦០០ តោន។ ទិន្នផលជាមធ្យម ១ ២១៧ គីឡូក្រាមក្នុង១ហិកតា។ តំបន់ភ្នំនិងខ្ពង់រាប បានរាយការណ៍ថា បានដាំស្វាយចន្ទី លើទំហំផ្ទៃដីប្រមាណ ៣១៦ ០០០ហិកតា។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ដំណាំយកប្រេង

ដំណាំយកប្រេង ដែលស្ថិតក្នុងការអង្កេតនេះរួមមាន ដូង និងដូងប្រេង។ ដូង ជាដំណាំដែលពេញនិយមជាងគេក្នុងចំណោមដំណាំទាំងពីរនេះ គ្រួសារកសិកម្មប្រមាណ ៥៤៦ ០០០ គ្រួសារ បានរាយការណ៍ថា បានដាំដំណាំដូង។ ផ្ទៃដីដាំដូងមានទំហំប្រមាណ ២៦ ០០០ ហិកតា ដោយផ្ទៃដីប្រមូលផលប្រមាណ ១២ ៥០០ ហិកតា។ បរិមាណផលសរុបប្រមូលបានប្រមាណ ១២៨ ៩០០តោន ជាមួយទិន្នផលជាមធ្យម ១០ ២៨២ គីឡូក្រាម ក្នុង១ហិកតា។ នៅតំបន់វាលទំនាប បានរាយការណ៍ថាបានដាំដូងច្រើនជាងគេបំផុត លើផ្ទៃដីប្រមាណ ៩ ០០០ហិកតា។



ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ដំណាំម្រេច

គ្រួសារដែលដាំម្រេច មានប្រមាណ ១០ ២០០ គ្រួសារ នៅប្រទេសកម្ពុជា។ ផ្ទៃដីដាំដុះម្រេចសរុបត្រូវបានប៉ាន់ប្រមាណថាមាន ៦ ០០០ ហិកតា និងផ្ទៃដីប្រមូលផល ៥ ០០០ ហិកតា។ ដំណាំម្រេចបានដាំច្រើនជាងគេ នៅតំបន់វាលទំនាប ដែលមានទំហំផ្ទៃដីដាំដុះប្រមាណ ៣ ៨០០ ហិកតា។

ដំណាំកៅស៊ូ

គ្រួសារកសិកម្មប្រមាណ ៥៦ ០០០គ្រួសារ ក្នុងប្រទេសកម្ពុជាបានដាំដំណាំកៅស៊ូ។ ផ្ទៃដីដាំកៅស៊ូសរុបមានប្រមាណ ១៦៤ ០០០ ហិកតា ដែលមានផ្ទៃដីប្រមូលប្រមាណ ១០២ ០០០ ហិកតា នៅកម្ពុជា។ បរិមាណផលសរុបប្រមូលបានប្រមាណ ២៩៧ ១០០ តោន ជាមួយទិន្នផលជាមធ្យមមានប្រមាណ ២ ៩២៦ គីឡូក្រាមក្នុង១ហិកតា។ សូមកត់ចំណាំថា ទិន្នន័យក្នុងរបាយការណ៍នេះ ប្រើតែកសិកម្មជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ ខណៈពេលដែលផលិតកម្មកៅស៊ូភាគច្រើន នៅក្នុងប្រទេសកម្ពុជាត្រូវបានកាន់កាប់ដោយក្រុមហ៊ុនកសិកម្មឯកជនធំៗមិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍នេះទេ។

ដំណាំមិនមែនស្បៀង

ដំណាំដែលមិនមែនជាអាហារមានផ្កា រុក្ខជាតិ និងដើមឈើ។ ឬស្សី ដែលប្រើប្រាស់សម្រាប់គោលបំណងជាច្រើនរួមទាំង សម្រាប់សាង់សង់ផ្ទះ គ្រឿងសង្ហារឹម និងការចម្អិនអាហារ គឺជាដំណាំមិនមែនអាហារនាំមុខគេ ដែលមានគ្រួសារកសិកម្មប្រមាណ ៦ ២០០ គ្រួសារ បានរាយការណ៍ថាបានដាំឬស្សី។ តំបន់បឹងទន្លេសាប គឺជាតំបន់ដែលមានចំនួនគ្រួសារដាំឬស្សីរហូតដល់ ៣ ០០០ គ្រួសារ។

តារាងឧបសម្ព័ន្ធ២

តារាងទី១៖ ដើមឈើ ឬដំណាំជារុក្ខជាតិការគណនាបំប្លែងពីការរាប់ចំនួនដើមឈើទៅជាហិកតា

ប្រភេទដើមឈើ/រុក្ខជាតិ	ការបំប្លែងឯកតាជាចំនួនដើម/ហិកតា
ក្រូចពោធិ៍សាត់	៤00
ក្រូចឃ្វិច	៤00
ក្រូចថ្លុង	៤00
ក្រូចឆ្មារ	៤00
ក្រូចសើច	៤00
ផ្លែក្រូចផ្សេងៗ	៤00
ចេក	១ ៦៦៧

ផ្លែទៀប	៤០០
ផ្លែទៀបបារាំង	៤០០
ផ្លែត្របែក	៤០០
ផ្លែមៀន	២៧៨
ស្វាយ	២៧០
ផ្លែល្អុង	១៦០០
ផ្លែម្នាស់	១៤ ០០០
ផ្លែខ្វិត	៤០០
ផ្លែខ្នុរ	២៧០
ចំប៉ាដក់	២៧០
ផ្លែទទឹម	៦០០
ល្មុត	២៧៨
ផ្លែសាវម៉ារ	១៥៦
ផ្លែមង្ឃុត	១០០
ផ្លែភ្ញៀវ	២៧០
អំពិលទឹក	៧០
ទុរេន	២៧០
ផ្លែទឹកដោះគោ	២៧០
ផ្លែឈូក	២៥ ០០០
ជម្ពូ	២៧៨
ផ្លែម៉ាក់ប្រាង	២៧០
ផ្លែម្កាក់	២៧៨
ផ្លែព្រីង	២៧០

ផ្លែពុទ្រា	២៧៨
ផ្លែគូលែន	១៥៦
ផ្លែស្ពឺ	៣០០
ផ្លែស្រកានាគ	២ ៥០០
ផ្លែទលឹងទឹង	៣០០
ផ្លែប៉ះស្យុង	១៥៦
ផ្លែកំពឹងរាជ	១០០
កន្ធត	៤០០
ផ្លែល្មើ	២០០
ផ្លែញ	៣០០
ផ្លែប័រ	២៨០
ដំណាំផ្លែផ្សេងៗ	២៨០
គ្រាប់ស្វាយចន្ទី	២៧៨
ស្លា	២ ៥០០
ឈូក	២៥ ០០០
ដំណាំភេសជ្ជៈផ្សេងៗ	១០០០
ដូង	២៧៨
ដូងប្រេង	២៧៨
ដើមត្នោត	១ ០០០
ម្រេច	២៥០០
ក្រសាំង	២៥០
អំពិល	៧០
ដំណាំគ្រឿងទេសផ្សេងៗ	១ ០០០

កៅស៊ូ	៥៥៥
ដំណាំយកជរ	៥00
ផ្កាម្លិះ	៥000
ផ្កាចន្ទូ	៣000
ផ្កាចំប៉ី	២00
ផ្កាម្លូ	២0000
ដំណាំផ្កាផ្សេងៗ	១៥00
ដើមចេកមាស	១៥000
ដើមខ្ចី	១0000
ដើមរាសី	១៥000
ឬស្សី	១0000
ដើមប្រេងខ្យល់	៧000
ឈើច័ន្ទគ្រឹស្នា	១៦00

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ផ្នែកទី៣: ការចិញ្ចឹមបសុសត្វ និងបសុបក្សី



វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

សហការជាមួយ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

Food and Agriculture Organization of the United Nations

ផ្នែកទី៣ ការចិញ្ចឹមបសុសត្វ និងបសុបក្សី

នៅក្នុងប្រទេសកម្ពុជា ការចិញ្ចឹមបសុសត្វ និងបសុបក្សី គឺជាសកម្មភាពកសិកម្មដ៏សំខាន់មួយដែលធ្វើឡើងដោយគ្រួសារកសិកម្ម ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ និងផ្តល់ប្រាក់ចំណូលដល់គ្រួសារនៅទីជនបទ។ ក្នុងចំណោមគ្រួសារកសិកម្មសរុបនៅប្រទេសកម្ពុជាមានគ្រួសារចូលរួមសកម្មភាពចិញ្ចឹមបសុសត្វ/បសុបក្សី/សត្វល្អិត ប្រមាណ ១,២ លានគ្រួសារ។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ បានបែងចែកបសុសត្វជាពីរ គឺប្រភេទបសុសត្វធំ (គោ និង ក្របី) និងប្រភេទបសុសត្វតូច (ជ្រូក និងពពែ)។


តារាងទី៣.១. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វ និងបសុបក្សី (គិតជាពាន់)

ប្រទេសកម្ពុជា (ចំនួនគ្រួសារ គិតជាពាន់)			
សរុប	បសុសត្វធំ (គោ ក្របី)	បសុសត្វតូច (ជ្រូក ពពែ)	បសុបក្សី (មាន់ ទា ត្រចៀកកាំ)
១ ២៣០	៦៦៨	១០៤	៩០៧

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


គ្រួសារកសិកម្មដែលបានចូលរួមធ្វើសកម្មភាពចិញ្ចឹមសត្វបានបង្ហាញថា បសុបក្សី និងបសុសត្វតូចភាគច្រើន គឺមាននៅតំបន់បឹងទន្លេសាប បន្ទាប់មកគឺតំបន់វាលទំនាប។ តែបសុសត្វធំ ត្រូវបានចិញ្ចឹម តំបន់វាលទំនាប ច្រើនជាងតំបន់បឹងទន្លេសាប។ តំបន់ភ្នំនិងខ្ពង់រាប មានការចិញ្ចឹមសត្វតិចជាងតំបន់ទាំងពីរខាងលើខណៈដែលតំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារ ដែលមានចិញ្ចឹមសត្វតិចជាងគេ។

រូបទី ៣.១. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹម បសុសត្វ បសុបក្សី តាមតំបន់ ឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


បសុសត្វធំ



ប្រភព: អង្គភាពកសិកម្មកម្ពុជាឆ្នាំ២០២៥


សត្វគោ

ជាទូទៅ បសុសត្វប្រភេទធំដែលគ្រួសារកសិកម្មបានចិញ្ចឹមច្រើនជាងគេ គឺសត្វគោ ដែលមានប្រមាណជា ២ ៨៣៣ ០០០ ក្បាល នៅទូទាំងប្រទេសកម្ពុជា។ តំបន់វាលទំនាប គឺជាតំបន់មួយដែលមានគ្រួសារចិញ្ចឹមគោច្រើនជាងគេ តែតំបន់បឹងទន្លេសាបជាតំបន់ដែលមានសត្វគោច្រើនជាងគេ (១ ០៥៦ ០០០ ក្បាល) ហើយជាបន្តបន្ទាប់ គឺតំបន់វាលទំនាប (១ ០១៧ ០០០ក្បាល)។ តំបន់ភ្នំនិងខ្ពង់រាប មានសត្វគោចំនួន ៦០៤ ០០០ក្បាល និងតំបន់ឆ្នេរសមុទ្រ ជាតំបន់ដែលមានចំនួនចិញ្ចឹមគោតិចជាងបំផុត (១៥៥ ០០០ក្បាល) បើប្រៀបធៀបទៅនឹងតំបន់ទាំងបួន។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

នៅទូទាំងប្រទេសកម្ពុជា ចំនួនសត្វគោគិតជាមធ្យម ប្រមាណ ៤,៥ក្បាល ក្នុង១គ្រួសារ។ គ្រួសារចិញ្ចឹមគោភាគច្រើន (៣៨៧,០០០គ្រួសារ) មានគោពី ៣ទៅ៩ក្បាល ហើយបន្ទាប់មក គឺពី ១ទៅ២ក្បាល មានចំនួន ២២៩,០០០គ្រួសារ និងមាន ៤១,០០០គ្រួសារ មានគោពី ១០ទៅ១៩ក្បាល និងមានតែ១១,០០០តែប៉ុណ្ណោះដែលបានរាយការណ៍ថាមានគោចាប់ពី២០ក្បាលឡើងទៅ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ចំនួនគោដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មភាគច្រើន គឺជាគោញី ក្នុងនោះគោញីប្រមាណ ១,៥ លានក្បាល (ប្រមាណជា ៥៣,១%) មានអាយុលើសពី២ឆ្នាំ ខណៈដែលគោឈ្មោលមានអាយុលើសពី២ឆ្នាំ មានចំនួនតិចតួចជាងគេ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ចំនួនគោដែលមានចិញ្ចឹមក្នុងគ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពីមេពូជច្រើនលើសលុប ជាងការទិញចូលយកមកចិញ្ចឹម។ នៅតំបន់វាលទំនាប មានចំនួនគោដែលបានកើតពីមេពូជមានច្រើនជាងគេ (២២៧ ០០០ក្បាល) បន្ទាប់មក គឺតំបន់បឹងទន្លេសាប (២០៧ ០០០ក្បាល) តំបន់ភ្នំនិងខ្ពង់រាប (១២៧ ០០០ក្បាល) និងតិចជាគេនៅតំបន់ឆ្នេរសមុទ្រ (២៥ ០០០ក្បាល)។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

បម្រែបម្រួលសត្វ គឺជាការកែប្រែប្រួលនូវចំនួនសត្វចិញ្ចឹមតាមគ្រួសារកសិកម្មក្នុងរយៈពេល១២ខែកន្លងមក ដូចជាការលក់ ការស្លាប់ សម្លាប់យកសាច់ ឬឱ្យទៅអ្នកផ្សេងជាដើម។ ការប្រែប្រួលចំនួនគោដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មនូវទូទាំងប្រទេសក្នុងរយៈពេល១២ខែកន្លងមក បានបង្ហាញថា ភាគច្រើនគឺការចិញ្ចឹមលក់រស់ (៧៩៤ ០០០ក្បាល) ហើយបន្ទាប់មក គឺការស្លាប់ដោយធម្មជាតិឬដោយជំងឺមាន ៦៦ ០០០ក្បាល ផ្តល់ជាអំណោយមាន ៥ ០០០ក្បាល ខណៈដែលការលួចមានចំនួនប្រមាណ ២ ០០០ ក្បាលដូចគ្នា។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥



រូបភាព: វិទ្យាស្ថានជាតិស្ថិតិ គ្រួសារចិញ្ចឹមគោ

សត្វក្របី

គ្រួសារដែលប្រកបរបរកសិកម្មដែលមានចិញ្ចឹមក្របីនៅទូទាំងប្រទេសកម្ពុជាបានរាយការណ៍ថា មានក្របីសរុបប្រមាណ ២១១ ០០០ក្បាល។ នៅតំបន់បឹងទន្លេសាប មានក្របីច្រើនជាងគេ (៩៩ ០០០ក្បាល) បន្ទាប់មកតំបន់វាលទំនាបមានចំនួន ៥៨ ០០០ក្បាល ហើយតំបន់ភ្នំនិងខ្ពង់រាប ដែលមានប្រមាណ ៣៩ ០០០ក្បាល និងតំបន់ឆ្នេរសមុទ្រ មានប្រមាណ ១៥ ០០០ក្បាល។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

នៅទូទាំងប្រទេសកម្ពុជា ចំនួនសត្វក្របីជាហ្វូងគិតជាមធ្យម ប្រមាណ ៥,២ក្បាល ក្នុង១គ្រួសារ។ គ្រួសារចិញ្ចឹមក្របីភាគច្រើន (២៤ ០០០គ្រួសារ) មានក្របីពី ៣ទៅ៩ក្បាល ហើយបន្ទាប់មក គឺពី ១ទៅ២ក្បាល មានចំនួន ១២ ០០០គ្រួសារ និងមានតែ ៥ ០០០គ្រួសារប៉ុណ្ណោះ ដែលបានរាយការណ៍ថាមានចិញ្ចឹមក្របីចាប់ពី ១០ក្បាលឡើងទៅ។




រូបភាព: វិទ្យាស្ថានជាតិស្ថិតិ គ្រួសារចិញ្ចឹមក្របី



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ចំនួនក្របីដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មភាគច្រើនគឺជាក្របីញី ដែលក្នុងនោះប្រមាណជា ៥២,៦% មានអាយុលើសពី២ឆ្នាំ ចំណែក ក្របីឈ្មោលមានអាយុលើសពី២ឆ្នាំ មានចំនួនតិចជាងគេ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


បសុសត្វតូច

សត្វជ្រូក

ប្រមាណជា ១០៤ ០០០គ្រួសារ នៃគ្រួសារកសិកម្មបានចិញ្ចឹមជ្រូកនៅទូទាំងប្រទេសកម្ពុជា។ គ្រួសារនៅតំបន់បឹងទន្លេសាបមានការចិញ្ចឹមជ្រូកច្រើនជាងគេ (៤២ ០០០គ្រួសារ) បន្ទាប់មក គឺ តំបន់វាលទំនាប (៣៣ ០០០គ្រួសារ) តំបន់ភ្នំនិងខ្ពង់រាប (១៩ ០០០ក្បាល) និងនៅតំបន់ឆ្នេរសមុទ្រមានគ្រួសារចិញ្ចឹមជ្រូកតិចជាងគេ (១០ ០០០គ្រួសារ)។




រូបភាព: វិទ្យាស្ថានជាតិស្ថិតិ គ្រួសារចិញ្ចឹមជ្រូក នៅខេត្តកំពង់ឆ្នាំង




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

នៅទូទាំងប្រទេសកម្ពុជា ចំនួនជ្រូកដែលបានចិញ្ចឹមគិតជាមធ្យមក្នុងមួយគ្រួសារ គឺ ៩,៣ ក្បាល។ គ្រួសារកសិកម្មដែលចិញ្ចឹមជ្រូកចន្លោះពី ១ទៅ២ក្បាល មានចំនួន ២៥ ០០០គ្រួសារ ចាប់ពី ៣ទៅ៩ក្បាល មានចំនួន ៤២ ០០០ គ្រួសារ ពី១០ទៅ១៩ ក្បាលមានចំនួន ២១ ០០០គ្រួសារ និងគ្រួសារដែលចិញ្ចឹមជ្រូកចាប់ពី ២០ ក្បាលឡើងមានចំនួន ១៣ ០០០គ្រួសារ ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ជ្រូកដែលចិញ្ចឹមក្នុងគ្រួសារភាគច្រើនជាសត្វដែលមានអាយុតិចជាង១ឆ្នាំ (ប្រមាណ ៧៦៥ ០០០ ក្បាល ឬ ៧៩% នៃជ្រូកទាំងអស់)។ លើសពីនេះ ជ្រូក ប្រមាណ ៥៨% នៃជ្រូកសរុបគឺ ជាជ្រូកញី។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ចំនួនជ្រូកដែលចិញ្ចឹមក្នុងគ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពីមេពូជជាជាងការទិញចូលយកមកចិញ្ចឹម។ នៅតំបន់បឹងទន្លេសាប ចំនួនជ្រូកដែលបានកើតពីមេពូជមានច្រើនជាងគេ (២៩៤ ០០០ ក្បាល) បន្ទាប់មក គឺតំបន់វាលទំនាប (២៣៨ ០០០ក្បាល) តំបន់ភ្នំ និងខ្ពង់រាប (៨៥ ០០០ក្បាល) និងតិចជាងគេនៅតំបន់ឆ្នេរសមុទ្រ (៥៦ ០០០ក្បាល)។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

បសុបក្សី



ប្រភព: អង្គភាពកសិកម្មកម្ពុជាឆ្នាំ២០២៥


ការប្រមូលទិន្នន័យអង្កេតកសិកម្មត្រូវបានប្រមូលព័ត៌មានពីការចិញ្ចឹមបសុបក្សីផងដែរ។ នៅក្នុងតារាងទិន្នន័យលទ្ធផលដែលបានផ្សព្វផ្សាយអំពីបសុបក្សី មានដូចជា មាន់ ទា និងក្ងាន ហើយរបាយការណ៍នេះផ្តោតតែលើការចិញ្ចឹមបសុបក្សីដែលសំខាន់ជាងគេ គឺសត្វមាន់ និងទា។



រូបភាព: វិទ្យាស្ថានជាតិស្ថិតិ គ្រួសារចិញ្ចឹមមាន់


សត្វមាន់

មាន់ គឺជាប្រភេទបសុបក្សីដែលគ្រួសារកសិកម្មបានចិញ្ចឹមច្រើនជាងគេមានចំនួន ៨៨៦ ៩២០ គ្រួសារ ស្មើនឹង ២២លានក្បាល នៅទូទាំងប្រទេស។ នៅតំបន់បឹងទន្លេសាប មានគ្រួសារចិញ្ចឹមមាន់ច្រើនជាងគេចំនួន ៣៣៨ ០០០គ្រួសារ បន្ទាប់មកតំបន់វាលទំនាប មាន ៣២៧ ០០០គ្រួសារ ហើយតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១២៦ ០០០គ្រួសារ និងតំបន់ឆ្នេរសមុទ្រមានចំនួន ៩៥ ០០០គ្រួសារ ។ ចំនួនមាន់ជាមធ្យមដែលចិញ្ចឹមក្នុងមួយគ្រួសារគឺ ២៥ក្បាល។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

នៅតំបន់បឹងទន្លេសាប បានរាយការណ៍ថាមានចំនួនមាន់ច្រើនជាងគេសរុបប្រមាណ ៨,៨ លានក្បាល។ នៅតំបន់វាលទំនាប មានចំនួន ៧,៤ លានក្បាល ហើយតំបន់ភ្នំ និងខ្ពង់រាប និងតំបន់ឆ្នេរសមុទ្រមានចំនួនប្រមាណ ៣,០ លានក្បាល។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ការចិញ្ចឹមមាន់របស់គ្រួសារកសិកម្មគឺបានមកពីការកើតកូនបន្តពូជ ច្រើនជាងលើសលុបពីការទិញមាន់ចូលយកមកចិញ្ចឹម។ នៅតំបន់វាលទំនាប មានមាន់កើតកូនបន្តពូជច្រើនជាងគេចំនួនប្រមាណ ៨,៤ លានក្បាល បន្ទាប់មកនៅតំបន់បឹងទន្លេសាបមាន ៨,៥លានក្បាល ហើយតំបន់ភ្នំ និងខ្ពង់រាបមានចំនួនប្រមាណ ២,៣ លានក្បាល និងតំបន់ឆ្នេរសមុទ្រមានចំនួនតិចជាងគេប្រមាណ ២,៤ លានក្បាល។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

បម្រែបម្រួលសត្វមាន់ទូទាំងប្រទេសភាគច្រើន គឺបណ្តាលមកពីការស្លាប់ដោយសារធម្មជាតិ និងជំងឺឆ្លងផ្សេងៗក្នុងរយៈពេល១២ ខែកន្លងមក។ មាន់ដែលបានស្លាប់មានចំនួនប្រមាណ ១០,៧លានក្បាល ឯការសម្លាប់យកសាច់ចំនួន ៦,៩លានក្បាល និងមាន់ដែលបានលក់ទាំងរស់មានចំនួន ៥,៧លានក្បាល។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥



រូបភាព: ការចិញ្ចឹមទាជាលក្ខណៈគ្រួសារ


សត្វទា

ទា គឺជាប្រភេទបសុបក្សីទី២ ដែលគ្រួសារកសិកម្មភាគច្រើនបានចិញ្ចឹម។ មានគ្រួសារកសិកម្មចំនួន ១១២ ៩០០ គ្រួសារដែលបានចិញ្ចឹមទា ជាមួយនឹងចំនួនទា ១២,៩លានក្បាល នៅទូទាំងប្រទេស។ នៅតំបន់វាលទំនាប មានគ្រួសារចិញ្ចឹមទាច្រើនជាងគេចំនួន ៥២ ០០០គ្រួសារ បន្ទាប់មកតំបន់បឹងទន្លេសាប មាន ៣៣ ០០០គ្រួសារ ហើយតំបន់ឆ្នេរសមុទ្រ មានចំនួន ១៥ ០០០គ្រួសារ និង តំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១៣ ០០០គ្រួសារ។ ចំនួនទាជាមធ្យមដែលចិញ្ចឹមក្នុងមួយគ្រួសារគឺ ១១៤ក្បាល។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

នៅតំបន់វាលទំនាប មានចំនួនទាសរុបប្រមាណ ៧,៤លានក្បាល ហើយតំបន់ឆ្នេរសមុទ្រ មានទាចំនួនប្រហែល ៧៦១ ៤០០ក្បាល។ ចំណែកឯចំនួនទានៅ តំបន់បឹងទន្លេសាប និងតំបន់ភ្នំ និងខ្ពង់រាបមិនបានបង្ហាញ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ក្នុងរយៈពេល១២ ខែកន្លងមក ការចិញ្ចឹមទារបស់គ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពូជច្រើនជាងលើសលប់ពីការទិញទាចូលយកមកចិញ្ចឹម។ នៅតំបន់វាលទំនាប មានទាកើតកូនបន្តពូជច្រើនជាងគេចំនួន ៨៣៥ ០០០ក្បាល បន្ទាប់មក គឺតំបន់បឹងទន្លេសាប មាន ៦៤៣ ០០០ក្បាល ហើយតំបន់ភ្នំ និងខ្ពង់រាប មានប្រមាណ ១៤៩ ០០០ក្បាល និងនៅតំបន់ឆ្នេរសមុទ្រ មានតិចជាងគេ ១៣៣ ០០០ក្បាល។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


បម្រែបម្រួលសត្វទាទូទាំងប្រទេសក្នុងរយៈពេល១២ ខែកន្លងមក នៃការចិញ្ចឹមទារបស់គ្រួសារកសិកម្ម បានបង្ហាញថា ការលក់រស់មានចំនួនប្រមាណ ៤,២ លានក្បាល ហើយចំនួន ១,០ លានក្បាល បានស្លាប់ដោយសារធម្មជាតិជំងឺ និងជំងឺឆ្លងផ្សេងៗ និងមាន ៤៨៣ ០០០ក្បាល ត្រូវបានសម្លាប់យកសាច់លក់ ឬធ្វើម្ហូប។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


ចំណីសត្វ

ការឱ្យសត្វស៊ីចំណីតាមធម្មជាតិត្រូវបានអនុវត្តភាគច្រើន ក្នុងចំណោមគ្រួសារកសិកម្មទាំងលើបសុសត្វ និងបសុបក្សី ខណៈការផ្តល់ចំណីសុទ្ធត្រូវបានអនុវត្តតិចតួចបំផុត។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


កាកសំណល់ផ្ទះបាយ ដូចជាកន្ទក់ ឬបាយស្រា ត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេសម្រាប់ជាចំណីបសុបក្សីដោយគ្រួសារកសិកម្ម ហើយដំណាំ/ស្មៅ/ស្លឹកឈើ(សម្រាប់សត្វ) និងចំណីកិនជាជម្រើសបន្ទាប់ ខណៈដែលដំណាំ/ស្មៅ/ស្លឹកឈើ(សម្រាប់សត្វ) ត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេសម្រាប់ជាចំណីបសុសត្វដោយគ្រួសារកសិកម្ម។ ចំណែកឯ ផលិតផលកសិឧស្សាហកម្ម ដូចជាកាកគ្រាប់ប្រេង ឬកាកស្រូវសាឡី (កាកប៊ីយែរ) និងសំណល់ដំណាំគឺត្រូវបានប្រើប្រាស់តិចតួចជាងគេទាំងលើបសុសត្វ និងបសុបក្សី។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


ប្រភពទឹកសំខាន់ៗ

អណ្តូងស្នប់ គឺជាប្រភពទឹកសំខាន់ទាំងក្នុងរដូវវស្សា និងរដូវប្រាំងដែលផ្តល់ដោយគ្រួសារកសិកម្ម ដល់បសុសត្វរបស់ពួកគេ។ ទឹកទន្លេ/ស្ទឹង/បឹង និងទឹកអណ្តូងជីក ជាប្រភពទឹកសំខាន់បន្ទាប់សម្រាប់ផ្តល់ដល់សត្វចិញ្ចឹម។ ចំណែកឯទឹកភ្លៀងគឺជាប្រភពទឹកសំខាន់ទី៤ សម្រាប់រដូវវស្សា។



ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


សម្រាប់បសុបក្សី ទឹកអណ្តូងស្នប់ និងអណ្តូងជីក គឺជាប្រភពទឹកសំខាន់ទាំងក្នុងរដូវវស្សា និងរដូវប្រាំងដែលផ្តល់ដោយគ្រួសារកសិកម្ម តែទឹកភ្លៀង គឺជាប្រភពទឹកសំខាន់ទី២ សម្រាប់រដូវវស្សា។



ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ការថែទាំសត្វ

ការចាក់វ៉ាក់សាំងបង្ការជំងឺ លើបសុសត្វធំ និងតូច របស់គ្រួសារកសិកម្មបានរាយការណ៍ថា មានចំនួនច្រើនលើសលប់ជាងសេវាកម្មពេទ្យសត្វផ្សេងៗ រួមទាំងការព្យាបាលជំងឺ និងការព្យាបាលប្រឆាំងនឹងប៉ារាស៊ីតខាងក្នុង និងខាងក្រៅ។ ទោះជាការចាក់វ៉ាក់សាំងបង្ការជំងឺលើសត្វមាន់របស់គ្រួសារកសិកម្ម មានចំនួនតិចជាងការព្យាបាលជំងឺសត្វ តែការចាក់វ៉ាក់សាំងបង្ការជំងឺលើសត្វមាន់មានចំនួនច្រើនទី២ ក្នុងចំណោមសេវាកម្មពេទ្យសត្វផ្សេងៗទាំងអស់។



ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ផ្នែកទី៤: ទារីវប្បកម្ម និងការនេសាទ













Food and Agriculture Organization of the United Nations

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

សហការជាមួយ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

ផ្នែកទី៤ វារីវប្បកម្ម និងការនេសាទ

វារីវប្បកម្ម និងនេសាទ ជាសកម្មភាពសេដ្ឋកិច្ចជំនួស ឬសកម្មភាពសេដ្ឋកិច្ចបន្ថែមសម្រាប់គ្រួសារកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជា។ ការអង្កេតកសិកម្មឆ្នាំ២០២៥ នេះ អាចប៉ាន់ស្មានថា គ្រួសារដែលបានកាន់កាប់កសិកម្មចំនួន ៦០ ១៣០ គ្រួសារ បានចូលរួមក្នុងសកម្មភាពវារីវប្បកម្ម ហើយមានគ្រួសារកាន់កាប់កសិកម្មចំនួន ៤០៩ ២៩០ គ្រួសារបានចូលរួមក្នុងសកម្មភាពនេសាទ។ មានគ្រួសារកាន់កាប់កសិកម្មចំនួន ២១ ៨៧០ គ្រួសារបានចូលរួមទាំងនៅក្នុងសកម្មភាពវារីវប្បកម្ម និងនេសាទ។ តំបន់ដែលមានចំនួនគ្រួសារច្រើនជាងគេក្នុងវិស័យវារីវប្បកម្ម គឺតំបន់វាលទំនាប ដែលមានគ្រួសារកាន់កាប់កសិកម្មចំនួន ៣៨ ៥៨០ គ្រួសារ បានរាយការណ៍ពីសកម្មភាពវារីវប្បកម្ម។ តំបន់ដែលមានចំនួនគ្រួសារច្រើនជាងគេបានចូលរួមក្នុងសកម្មភាពនេសាទ គឺ តំបន់បឹងទន្លេសាប មានចំនួន ២០៦ ២០០ គ្រួសារ ដែលបានរាយការណ៍ពីសកម្មភាពនេសាទ។

វារីវប្បកម្ម




រូបភាព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២៥ ស្រះចិញ្ចឹមត្រីនៅខេត្តតាកែវ

វារីវប្បកម្ម គឺសំដៅទៅលើវប្បកម្មវារីជាតិនៅក្នុងសមុទ្រ បឹង ទន្លេ និងតំបន់វាលល្បាប់ ឬដែនទឹកផ្សេងទៀត ដូចជា ស្រះ វាលស្រែ ឬតំបន់ផ្សេងទៀត នៅក្រោមការគ្រប់គ្រង។ ក្នុងចំណោមសកម្មភាពខុសៗគ្នានៃវារីវប្បកម្មដែលបានប្រមូលទិន្នន័យនៅក្នុងការអង្កេតកសិកម្មឆ្នាំ២០២៥ ការធ្វើវារីវប្បកម្មនៅក្នុងស្រះ បែរ


ទ្រុង វាលស្រែ តង់/លូ/ធុង/ស្គរ/អាង អាងភ្ញាស់/អាងបំប៉ន កន្លែងផ្សាំ ឬសកម្មភាពវារីវប្បកម្មដទៃទៀត ដែលក្នុងនោះសកម្មភាពដែលមានច្រើនជាងគេ គឺការធ្វើវារីវប្បកម្មក្នុងស្រះដែលមានគ្រួសារកសិកម្មចំនួន ៤៥ ៨៨០ គ្រួសារ បានឆ្លើយពីវារីវប្បកម្មនៅក្នុងស្រះ។ មានគ្រួសារកសិកម្មត្រឹមតែ ៨ ១២០ គ្រួសារកសិកម្មបានធ្វើវារីវប្បកម្មក្នុងបែរ។ ហើយ ៥ ២៧០ គ្រួសារកសិកម្ម បានប្រើប្រាស់លូ/ធុង/ស្គរ/អាង ឬទ្រុង។ ផ្ទៃដីសរុបដែលបានប្រើប្រាស់សម្រាប់ធ្វើវារីវប្បកម្មក្នុងគ្រួសារកាន់កាប់កសិកម្មមាន ១ ៣៩០ ហិកតា ក្នុងនោះ តំបន់ដែលមានការកាន់កាប់សកម្មភាពវារីវប្បកម្មច្រើនជាងគេ គឺតំបន់វាលទំនាប ដែលមានផ្ទៃដី ៨៩០ ហិកតា។

រូបទី ៤.១ ចំនួនគ្រួសារកសិកម្ម ដែលរាយការណ៍អំពីសកម្មភាពវារីវប្បកម្មតាមតំបន់ ឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ការចិញ្ចឹមតាមវារីវប្បកម្ម ចំនួនត្រីដែលមាននៅថ្ងៃសម្ភាសន៍សម្រាប់ការអង្កេតនេះ គ្រួសារដែលចិញ្ចឹមត្រីប្រា (មានចំនួន ៣៩ ១៦០ គ្រួសារ) និងគ្រួសារបានចិញ្ចឹមត្រីអណ្តែង (មានចំនួន ៩ ៦៩០ គ្រួសារកាន់កាប់កសិកម្ម)។ ចំណែកត្រីរ៉ស់ ត្រីទីឡាព្យា ត្រីឆ្តិន កង្កែប និងត្រីឆ្តោក គឺជាប្រភេទត្រីចិញ្ចឹមសម្រាប់ប្រើប្រាស់ក្នុងគ្រួសារតែប៉ុណ្ណោះ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


ការនេសាទត្រី



រូបភាព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២៥ នេសាទត្រី នៅខេត្តតាកែវ


ការអង្កេតកសិកម្មឆ្នាំ២០២៥ សកម្មភាពនេសាទត្រូវបានបែងចែកតាមប្រភេទទឹកសាប (ទន្លេ ឬបឹង) ទឹកសមុទ្រ ទឹកភ្លាវ ឬតាមវាលស្រែ។ សកម្មភាពនេសាទ រួមមាន ការនេសាទត្រី និងវារីជាតិដទៃទៀតក្នុង

សមុទ្រ តំបន់ឆ្នេរសមុទ្រ និងក្នុងដែនទឹកសាបនានា ដោយមាន ឬមិនមានការប្រើប្រាស់ទូក ឬឧបករណ៍នេសាទឯកទេស។ ការនេសាទនេះ គិតចាប់ពីពេលណាមួយក្នុងអំឡុងឆ្នាំយោងនៃអង្កេតឆ្នាំ២០២៥ ដោយគិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។ យោងតាមការអង្កេតកសិកម្ម បានប៉ាន់ប្រមាណថា តំបន់បឹងទន្លេសាប មានគ្រួសារកសិកម្មធ្វើនេសាទច្រើនជាងគេ មានចំនួន ២០៦ ២០០ គ្រួសារ ដែលបានចូលរួមក្នុងសកម្មភាពនេសាទ ក្នុងនោះមានតំបន់វាលទំនាបមានចំនួន១០០ ០៧០ គ្រួសារកសិកម្ម ឬតំបន់ភ្នំ និងខ្ពង់រាប មានចំនួន៧៥ ៦៦០ គ្រួសារកសិកម្ម និងតំបន់ឆ្នេរសមុទ្រមានចំនួន ២៧ ៣៦០ គ្រួសារកសិកម្មដែលបានរាយការណ៍ពីសកម្មភាពនេសាទ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


សកម្មភាពនេសាទដែលបានរាយការណ៍ដោយគ្រួសារភាគច្រើនកើតឡើងនៅក្នុងវាលស្រែ (មានចំនួន ២៦៩ ៦៣០ គ្រួសារ) និងនៅក្នុងទន្លេ ឬបឹងបួរ (មានចំនួន ១៩៤ ០៧០ គ្រួសារ) ។ បើធៀបទៅនឹងរបាយការណ៍នៃគ្រួសារតិចតួចដែលបានចាប់យកការនេសាទនៅក្នុងទឹកសមុទ្រ(មានចំនួន ៨ ០១០ គ្រួសារ) និងនេសាទទឹកភ្លៀវ (មានចំនួន ៣៥០ គ្រួសារប៉ុណ្ណោះ)។



រូបទី ៤.៤ ចំនួនគ្រួសារកាន់កាប់កសិកម្មដែលពាក់ព័ន្ធសកម្មភាពផលត្រីនេសាទនៅកម្ពុជាឆ្នាំ២០២៥ គិតតាមប្រភេទ

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ផលនេសាទត្រីសរុប ត្រូវបានរាយការណ៍ថាមាន ២២៦លានគីឡូក្រាម មានការថយចុះជាងរាល់ឆ្នាំបើប្រៀបធៀបផលនេសាទក្នុងឆ្នាំកន្លងមក។ ច្រើនជាងពាក់កណ្តាលនៃអ្នកឆ្លើយ បើយោងតាមទិន្នន័យនៃការធ្វើអង្កេតឆ្នាំ២០២៥ នេះ(មាន ៧០,១%) នៃគ្រួសារកសិកម្មដែលបានរាយការណ៍ថាផលនេសាទក្នុងឆ្នាំបច្ចុប្បន្នបានផលប្រហាក់ប្រហែលនឹងផលនេសាទកាលពីឆ្នាំមុន ៩,២% នៃគ្រួសារកសិកម្មបានរាយការណ៍ថាផលបានកើនច្រើនជាងបើប្រៀបធៀបនឹងឆ្នាំមុន ២០,៨% បានរាយការណ៍ថា ការនេសាទទាបជាង បើប្រៀបធៀបនឹងឆ្នាំមុន។




រូបទី ៤.៥ ការប្រៀបធៀបរវាងផលនេសាទក្នុងឆ្នាំបច្ចុប្បន្នទៅឆ្នាំមុន នៃគ្រួសារកសិកម្ម ឆ្នាំ២០២៥

ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ការអង្កេតកសិកម្ម ឆ្នាំ២០២៥ បានប្រមូលទិន្នន័យអំពីវារីជាតិជាច្រើនប្រភេទដែលបាននេសាទក្នុងនោះរួមមាន ត្រី ក្តាម ខ្យង និងអន្ទង់។ ប្រមាណជា ៧៨% គ្រួសារបានរាយការណ៍ពីសកម្មភាពនេសាទត្រី (ស្មើនឹង ៣៩៩ ៦២០ គ្រួសារ) ១៣% នេសាទក្តាម (ស្មើនឹង ៦៨ ០២០ គ្រួសារ) ៦% នេសាទខ្យង (ស្មើនឹង ៣០ ៩៥០ គ្រួសារ) និង ២% បាននេសាទអន្ទង់ (ស្មើនឹង ១១ ០៩០ គ្រួសារ)។

ឧបករណ៍នេសាទជាច្រើនប្រភេទត្រូវបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា។ តាមលទ្ធផលនៃការអង្កេតកសិកម្មឆ្នាំ២០២៥ នេះបានប៉ាន់ស្មានថា តើមានគ្រួសារប៉ុន្មានបានប្រើប្រាស់ឧបករណ៍នីមួយៗក្នុងសកម្មភាពនេសាទរបស់ពួកគេ។ ឧបករណ៍នេសាទដែលគ្រួសារបានប្រើប្រាស់ភាគច្រើន គឺមង (មានប្រមាណ ២៤៣ ០១០ គ្រួសារ) សំណាញ់ (មានប្រមាណ ១៦៦ ៦៦០ គ្រួសារ) ទ្រូ (មាន ៧៥ ៩២០ គ្រួសារ) ចាប់ដោយដៃមាន (៥៦ ០៨០ គ្រួសារ) និងការប្រើប្រាស់សន្ទូចផ្លែមួយមាន (៣៥ ១៨០ គ្រួសារ) ក្រៅពីនេះមានគ្រួសារជាច្រើនទៀតប្រើឧបករណ៍នេសាទផ្សេងៗទៀត។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ផ្នែកទី៥: កម្លាំងពលកម្ម និងសកម្មភាពសេដ្ឋកិច្ច













Food and Agriculture Organization of the United Nations

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

សហការជាមួយ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

ផ្នែកទី៥ កម្លាំងពលកម្ម សកម្មភាពសេដ្ឋកិច្ច គ្រោះហានិភ័យ និងប្រាក់កម្ចី


អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២៥ គ្របដណ្តប់ការឆ្លាស់គ្នានៃម៉ូឌុល (Module) ហើយបានរួមបញ្ចូលសំណួរពាក់ព័ន្ធនឹងសូចនាករសេដ្ឋកិច្ច ដើម្បីឆ្លើយតបគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២.៤.១ ។ ម៉ូឌុលនេះ បានរួមបញ្ចូលសំណួរជាច្រើនទាក់ទងនឹងការចំណូលចំណាយនៃកសិដ្ឋាន។ លើសពីនេះរបាយការណ៍ក៏បានបញ្ចូលផងដែរ នូវលទ្ធផលដែលពាក់ព័ន្ធនឹងកម្លាំងពលកម្ម គ្រោះហានិភ័យ និងប្រាក់កម្ចី ដែលជះឥទ្ធិពលលើសេដ្ឋកិច្ចគ្រួសារកសិកម្ម។



ប្រភពរូបភាព: វិទ្យាស្ថានជាតិស្ថិតិ គ្រួសារចិញ្ចឹមគោ


កម្លាំងពលកម្ម

នៅតំបន់បឹងទន្លេសាប សមាជិកគ្រួសារកសិកម្មបានចូលរួមចំណែកធ្វើការងារកសិកម្មច្រើនជាងគេ មានភេទប្រុសចំនួនប្រមាណ ៩៦៦ ០០០នាក់ និងភេទស្រីចំនួនប្រមាណ ៩៨០ ០០០នាក់ បន្ទាប់មកនៅតំបន់វាលទំនាប ហើយតំបន់ភ្នំ និងខ្ពង់រាប និងនៅតំបន់ឆ្នេរសមុទ្រ មានសមាជិកគ្រួសារតិចជាងគេដែលធ្វើការងារកសិកម្មក្នុងកសិដ្ឋាន។ សមាជិកគ្រួសារកសិកម្មភេទស្រី និងភេទប្រុស គឺមានសមាមាត្រប្រហាក់ប្រហែលគ្នានៅក្នុងតំបន់នីមួយៗ។ សម្រាប់តំបន់បឹងទន្លេសាប មានភាពខុសគ្នាខ្លះ សមាជិកគ្រួសារជាភេទប្រុសមានប្រមាណ ៥១% និងសមាជិកគ្រួសារជាភេទស្រីមានប្រមាណ ៤៩% ដែលបានចូលរួមធ្វើការងារក្នុងកសិដ្ឋាន។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

រូបភាព ៥.២ បង្ហាញចំនួនម៉ោងធ្វើការងារជាមធ្យមរបស់សមាជិកគ្រួសារភេទស្រី និងភេទប្រុសក្នុងកសិដ្ឋាន។ ទិន្នន័យបានបង្ហាញថាភេទប្រុសបានចំណាយម៉ោងធ្វើការងារក្នុងកសិដ្ឋានច្រើនជាងភេទស្រី គ្រប់តំបន់ទាំងបួននៃប្រទេសកម្ពុជា។ ចំពោះនៅតំបន់ភ្នំ និងខ្ពង់រាបមាជិកគ្រួសារជាភេទប្រុសបានចំណាយម៉ោងធ្វើការងារជាមធ្យមប្រមាណ ៧៦៩ ម៉ោងបើប្រៀបធៀបទៅនិងសមាជិកគ្រួសារជាភេទស្រីបានចំណាយម៉ោងធ្វើការងារជាមធ្យមប្រមាណ ៦១៣ ម៉ោងក្នុងកសិដ្ឋាន។ ដូចគ្នានេះដែរ ទិន្នន័យបានបង្ហាញថា នៅតំបន់បឹងទន្លេសាប តំបន់វាលទំនាប និងតំបន់ឆ្នេរសមុទ្រមានជាលំដាប់លំដោយរៀងគ្នា។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ការដាំដុះដំណាំ គឺជាប្រភេទសកម្មភាពកសិកម្ម ដែលគ្រួសារកាន់កាប់កសិកម្មបានចំណាយពេលធ្វើការងារច្រើនជាងគេបំផុត។ គ្រួសារកាន់កាប់កសិកម្មបានចំណាយពេលធ្វើការងារលើការដាំដុះដំណាំសរុបមានប្រមាណ ៦៦,២%។ សកម្មភាពរបស់គ្រួសារកាន់កាប់កសិកម្មបានចំណាយពេលធ្វើការងារធំទីពីរគឺការចិញ្ចឹមបសុសត្វ ឬបសុបក្សី ដែលមានប្រមាណ ៤៣,១%។ គ្រួសារកាន់កាប់កសិកម្មបានចំណាយពេលធ្វើការងារលើវារីវប្បកម្ម ឬសកម្មភាពនេសាទមានប្រមាណ ១៨,០% និងសកម្មភាពប្រមូលអុស ឈើ ឬផលិតផលពីព្រៃ មានប្រមាណ ១២,៧%។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

រូបភាព ៥.៤ បានបង្ហាញអំពីចំនួនកសិដ្ឋានដែលជួលកម្មករពីខាងក្រៅតាមតំបន់ផ្សេងៗគ្នា។ ទិន្នន័យបានបង្ហាញថានៅតំបន់វាលទំនាប បានជួលកម្មករពីខាងក្រៅមានចំនួនខ្ពស់ជាងគេ គឺប្រមាណ ៦ ០០០គ្រួសារ បន្ទាប់មកគឺតំបន់បឹងទន្លេសាបប្រហែល ៥ ០០០គ្រួសារ និងតំបន់ភ្នំ និងខ្ពង់រាប ប្រមាណ ៣ ០០០គ្រួសារ ដែលបានកាន់កាប់កសិកម្មបានជួលកម្មករពីខាងក្រៅ។ ទោះជាយ៉ាងណានៅតំបន់ឆ្នេរសមុទ្រ មិនមានការបង្ហាញអំពីទិន្នន័យលម្អិតទេ ដោយសារការឆ្លើយតបមិនបានឱ្យកៀកនឹងស្ថិតិលម្អិត។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


រូបភាព ៥.៥ បានបង្ហាញអំពីចំនួនសរុបនៃកម្មករជួលពីខាងក្រៅធ្វើការពេញម៉ោងតាមភេទ។ លទ្ធផលបានបង្ហាញថា ចំនួនអ្នកធ្វើការងារកសិកម្មជាភេទប្រុសមានប្រមាណ ៣០ ០០០ គឺខ្ពស់ជាងចំនួនអ្នកធ្វើការងារកសិកម្មជាភេទស្រីមានប្រមាណ ១៨ ០០០ នៅទូទាំងប្រទេស។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


រូបភាព ៥.៦ បង្ហាញចំនួនគ្រួសារកសិកម្មមានជួលកម្មករធ្វើការម្តងម្កាលតាមតំបន់។ ចំនួននៃកសិដ្ឋានមានជួលកម្មករធ្វើការម្តងម្កាល គឺខ្ពស់ជាងកម្មករជួលពីខាងក្រៅ (រូបភាព ៥.៤ ខាងលើ)។ តំបន់បឹងទន្លេសាបមានចំនួនខ្ពស់ជាងគេគឺមានចំនួនប្រមាណ ១៤៧ ០០០ កសិដ្ឋានដែលជួលកម្មករធ្វើការម្តងម្កាល។ តំបន់វាល

ទំនាបមានប្រមាណ ៧៩ ០០០ កសិដ្ឋាន តំបន់ភ្នំ និងខ្ពង់រាបមានប្រមាណ ៥៣ ០០០ កសិដ្ឋាន និងតំបន់ឆ្នេរសមុទ្រមានប្រមាណ ៨ ០០០ កសិដ្ឋាន។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


រូបភាព ៥.៧ បានបង្ហាញចំនួនកម្មករធ្វើការម្តងម្កាលតាមភេទ។ នៅតំបន់បឹងទន្លេសាប បង្ហាញចំនួនកម្មករធ្វើការម្តងម្កាលភេទប្រុសច្រើនជាងចំនួនកម្មករធ្វើការម្តងម្កាលដែលជាភេទស្រី។ តែទោះជាយ៉ាងណាក៏ដោយ នៅតំបន់វាលទំនាប បានបង្ហាញថាចំនួនកម្មករជាភេទប្រុសធ្វើការម្តងម្កាលមានប្រមាណ ១៨៥ ០០០ ខ្ពស់ជាងកម្មករធ្វើការម្តងម្កាលដែលជាភេទស្រីមានប្រមាណ ១១១ ០០០ ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


កសិដ្ឋាននៅតំបន់ឆ្នេរសមុទ្របានរាយការណ៍ថា ការចំណាយប្រាក់ឈ្នួលលើកម្មករធ្វើការម្តងម្កាលមានចំនួនខ្ពស់ជាងគេ គឺប្រមាណ៩,១ដុល្លារ ក្នុង១ថ្ងៃ។ នៅតំបន់ភ្នំ និងខ្ពង់រាបក៏បានរាយការណ៍ថា ប្រាក់ឈ្នួលជាមធ្យមរបស់កម្មករធ្វើការម្តងម្កាលមានប្រមាណ ៧,៣ដុល្លារ ក្នុង១ថ្ងៃ។ ម្យ៉ាងវិញទៀតចំណែកតំបន់វាលទំនាបក៏បានរាយការណ៍ថាប្រាក់ឈ្នួលជាមធ្យម របស់កម្មករធ្វើការម្តងម្កាលមានការថយចុះជាលំដាប់ប្រមាណ ៦,០ ដុល្លារ ក្នុង១ថ្ងៃ ។

រូបទី ៥.៨ ប្រាក់ឈ្នួលជាមធ្យមក្នុង១ថ្ងៃសម្រាប់កម្មករធ្វើការម្តងម្កាល តាមតំបន់ ឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

រូបភាព ៥.៩ បង្ហាញអំពីប្រាក់ឈ្នួលប្រចាំខែជាមធ្យមសម្រាប់កម្មករជួលពីខាងក្រៅនៅតាមតំបន់។ កម្មករជួលពីខាងក្រៅនៅតំបន់ឆ្នេរសមុទ្រ មានប្រាក់ឈ្នួលប្រចាំខែជាមធ្យមខ្ពស់ជាងគេប្រមាណ ២៨១ដុល្លារ ក្នុង១ខែ។ តំបន់ភ្នំ និងខ្ពង់រាបមានប្រាក់ឈ្នួលប្រចាំខែជាមធ្យមសម្រាប់កម្មករជួលពីខាងក្រៅមានប្រមាណ ២២៦ដុល្លារ។ ចំណែកនៅតំបន់ទាំងបីផ្សេងទៀតបានរាយការណ៍ថា ប្រាក់ឈ្នួលប្រចាំខែជាមធ្យមសម្រាប់កម្មករជួលពីខាងក្រៅមាន ប្រហាក់ប្រហែលគ្នាចំនួនប្រមាណ ១៩១ដុល្លារ ក្នុង១ខែ សម្រាប់នៅតំបន់បឹងទន្លេ សាប និង ១៨៥ ដុល្លារ សម្រាប់តំបន់វាលទំនាប។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥



រូបភាព: វិទ្យាស្ថានជាតិស្ថិតិ គ្រួសារដាំសណ្តែកគួរនៅដីលំនៅឋាន


សកម្មភាពសេដ្ឋកិច្ច

រូបភាព ៥.១០ បង្ហាញពីចំនួនអ្នកធ្វើការឱ្យកសិដ្ឋានផ្សេងទៀតបែងចែកតាមតំបន់។ ទិន្នន័យបានបង្ហាញថា តំបន់ភ្នំ និងខ្ពង់រាបមានចំនួនអ្នកធ្វើការឱ្យកសិដ្ឋានផ្សេងច្រើនជាងគេមាន ៥២ ០០០ ដោយតំបន់បឹងទន្លេសាបមាន ៤៩ ០០០ តំបន់វាលទំនាបមាន ៣៩ ០០០ តំបន់ឆ្នេរសមុទ្រមាន ៣ ០០០។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

រូបភាព ៥.១១ បង្ហាញពីការចំណាយថ្លៃប្រេងឥន្ធនៈនៅអំឡុងរដូវប្រាំង និងរដូវវស្សា សម្រាប់សកម្មភាពកសិកម្មពេញមួយឆ្នាំ។ ការចំណាយច្រើនបំផុតគឺនៅតំបន់បឹងទន្លេសាប ដែលនៅរដូវប្រាំងប្រហែល ៣៨ដុល្លារ និង រដូវវស្សាប្រហែល ៤០,៥០ដុល្លារ។ ដោយនៅតំបន់ភ្នំ និងខ្ពង់រាប អំឡុងរដូវប្រាំងប្រហែល ២៥,៥០ ដុល្លារ និង អំឡុងរដូវវស្សាប្រហែល ៣២ដុល្លារ នៅតំបន់ឆ្នេរសមុទ្រចំណាយនៅរដូវប្រាំងប្រហែល ២៧,២៥ ដុល្លារ និង រដូវវស្សាប្រហែល ២៧,២៥ ដុល្លារ សម្រាប់តំបន់វាលទំនាបមានការចំណាយសម្រាប់រដូវប្រាំងប្រហែល ២៨,៧៥ដុល្លារ រដូវវស្សាប្រហែល ១៦,៧៥ ដុល្លារ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

រូបភាព ៥.១២ បង្ហាញថា គ្រួសារកាន់កាប់កសិកម្មមានប្រមាណ ៧៨៤ ០០០ ធ្វើកសិកម្មជាចម្បងសម្រាប់លក់ និងគ្រួសារកាន់កាប់កសិកម្មប្រមាណ ៥៦០ ០០០ ជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ដោយឡែកគ្រួសារកាន់កាប់កសិកម្មចំនួនប្រមាណ ៤៦០ ០០០ ធ្វើកសិកម្មសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ និងប្រមាណ ៧១ ០០០គ្រួសារធ្វើកសិកម្មសម្រាប់តែលក់ប៉ុណ្ណោះ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ចំនួនគ្រួសារកាន់កាប់កសិកម្មប្រមាណ ៦៤៦ ០០០ បានរាយការណ៍ថា ប្រហែលពាក់កណ្តាលនៃគ្រួសារកាន់កាប់កសិកម្មទាំងនោះមានចំណូលមកពីសកម្មភាពកសិកម្ម (៤០-៥៩ ភាគរយ)។ មានតែគ្រួសារកសិកម្មប្រមាណ ១១៧ ០០០ បានរាយការណ៍ថា មានចំណូលសរុបពឹងផ្អែកតែលើទិន្នផលកសិកម្ម។ គ្រួសារកសិកម្មជាច្រើនប្រហែលបីដងគឺ ២១១ ០០០ បានរាយការណ៍ថា ប្រាក់ចំណូលរបស់គ្រួសារបានមកពីសកម្មភាពកសិកម្មមានតិចជាង ១០ ភាគរយ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

រូបភាព ៥.១៤ បានបង្ហាញពីការចូលរួមរបស់គ្រួសារកាន់កាប់កសិកម្ម នៅក្នុងសមាគមកសិករក្រៅផ្លូវការ និងផ្លូវការ (បានចុះបញ្ជីជាមួយរដ្ឋាភិបាល)។ ទាំងសមាគមកសិករផ្លូវការ និងក្រៅផ្លូវការ គឺមានចំនួនច្រើនជាងគេនៅក្នុងតំបន់ភ្នំនិងខ្ពង់រាប។

រូបទី ៥.១៤ ការចូលរួមនៅក្នុងសមាគមកសិករផ្លូវការ ឬសមាគមកសិករក្រៅផ្លូវការតាមតំបន់ ឆ្នាំ២០២៥




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ប្រាក់កម្ចី

លទ្ធភាពទទួលបានហិរញ្ញប្បទានមានសារៈសំខាន់ណាស់ សម្រាប់គ្រួសារកាន់កាប់កសិកម្មខ្នាតតូចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារមូលហេតុមួយចំនួនរួមមាន ការកែលម្អ ផលិតភាព ការគ្រប់គ្រងហានិភ័យការដំណើរការទៅកាន់ទីផ្សារ ការរៀបចំខ្លួនចំពោះគ្រោះមហន្តរាយ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម។


នៅតំបន់បឹងទន្លេសាប មានគ្រួសារកាន់កាប់កសិកម្មចំនួន ២១៣ ០០០ គ្រួសារ បានរាយការណ៍ថាមានកម្ចីឥណទានយ៉ាងហោចណាស់មួយ បន្ទាប់មកតំបន់វាលទំនាបមាន ២០០ ០០០ គ្រួសារ តំបន់ភ្នំនិងខ្ពង់រាបមាន ៩៥ ០០០ គ្រួសារ និងតំបន់ឆ្នេរសមុទ្រមាន ២៤ ០០០ គ្រួសារ។

រូបទី ៥.១៥ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថាមានសមាជិកយ៉ាងតិចម្នាក់ដែលមានកម្ចីឥណទាន តាមតំបន់ ឆ្នាំ២០២៥




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

គ្រួសារកាន់កាប់កសិកម្មប្រហែល ៥៧ភាគរយ បានប្រើប្រាស់ប្រាក់កម្ចីរបស់ពួកគេសម្រាប់គោលបំណងកសិកម្ម។ នៅតំបន់បឹងទន្លេសាប គ្រួសារកាន់កាប់កសិកម្មដែលបានរាយការណ៍ថាប្រើប្រាស់ប្រាក់កម្ចីរបស់ពួកគេមួយផ្នែកសម្រាប់គោលបំណងកសិកម្មមាន ១៤៣ ០០០ គ្រួសារ បន្ទាប់មកគឺតំបន់វាលទំនាបមាន ៩៥ ០០០ គ្រួសារ តំបន់ភ្នំនិងខ្ពង់រាបមាន ៥២ ០០០ គ្រួសារ និង តំបន់ឆ្នេរសមុទ្រ មាន ១១ ០០០គ្រួសារ។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

ប្រាក់កម្ចីច្រើនបំផុតត្រូវបានខ្ចីតាមរយៈធនាគារ។ ជាសរុបគ្រួសារកាន់កាប់កសិកម្មមានចំនួនប្រមាណ ២៤១ ០០០ គ្រួសារ បានរាយការណ៍ថា បានប្រើប្រាស់ធនាគារសម្រាប់ប្រាក់កម្ចី យ៉ាងហោចណាស់មួយកម្ចីចំនួនប្រើប្រាស់ច្រើនលំដាប់ទីពីរ គឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានប្រមាណ ២៣១ ០០០គ្រួសារ។ ក្រៅពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ មានប្រភពផ្តល់ប្រាក់កម្ចីក្រៅផ្លូវការដូចជា សាច់ញាតិ អ្នកចងការប្រាក់ មិត្តភក្តិ ឬអ្នកជិតខាងក៏ត្រូវបានរាយការណ៍ផងដែរ។

រូបទី ៥.១៧ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថាយ៉ាងហោចណាស់សមាជិកគ្រួសារម្នាក់មានប្រាក់កម្ចី តាមប្រភពនៃប្រាក់កម្ចី ឆ្នាំ២០២៥




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥


គ្រោះហានិភ័យ

គ្រោះហានិភ័យសំដៅទៅលើព្រឹត្តិការណ៍កើតមានឡើង ដែលមិនបានគិតទុកជាមុនហើយប៉ះពាល់យ៉ាងខ្លាំងដល់ផលិតកម្ម ឬទីផ្សារ។ នោះអាចអាស្រ័យលើកត្តាធម្មជាតិ ដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ សត្វល្អិតចង្រៃបំផ្លាញ ឬជម្ងឺដែលអាចនាំឱ្យដំណាំខូច ប៉ុន្តែពួកគេក៏អាចបង្កើតដោយមនុស្សផងដែរ ដូចជាការផ្លាស់ប្តូរគោលនយោបាយរដ្ឋាភិបាល ការរឹតបន្តឹងពាណិជ្ជកម្ម ឬជម្លោះដែលរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់។ គ្រោះហានិភ័យទាំងនេះអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យ កសិកម្ម និងសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ។ បញ្ហាទាំងនេះហើយដែលអាចនាំឱ្យមានការកើនឡើងតម្លៃស្បៀង កាត់បន្ថយប្រាក់ចំណូលសម្រាប់កសិករ និងការកើនឡើងនៃភាពក្រីក្រ និងអសន្តិសុខស្បៀងក្នុងចំណោមប្រជាជនដែលងាយរងគ្រោះ។

នៅក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥ នៅតំបន់បឹងទន្លេសាបមានគ្រួសារកាន់កាប់កសិកម្មច្រើនជាងគេដែលរាយការណ៍ថា បានជួបគ្រោះហានិភ័យស្ទើរតែពេញមួយឆ្នាំប្រមាណ ១៥៣ ០០០ ។ ចំពោះនៅតំបន់ឆ្នេរសមុទ្រ បានរាយការណ៍ថា គ្រួសារកាន់កាប់កសិកម្ម ជួបគ្រោះហានិភ័យមានចំនួនទាបជាងគេប្រមាណ ៩ ០០០ ។




ប្រភព: អង្គភាពកសិកម្មកម្ពុជាឆ្នាំ២០២៥




ប្រភព: អង្គភាពកសិកម្មកម្ពុជាឆ្នាំ២០២៥

យោងទៅតាមគ្រោះហានិភ័យធ្ងន់ធ្ងរនៃគ្រួសារកសិកម្ម ដែលបានជួបប្រទះភាគច្រើនគឺគ្រោះរាំងស្ងួត ដែលប៉ះពាល់ដល់គ្រួសារកសិកម្ម មានចំនួនប្រមាណ ៩០ ០០០ ក្នុងឆ្នាំ២០២៥។ គ្រោះហានិភ័យធំទីពីរ គឺ ទឹកជំនន់ ដែលមានគ្រួសារកសិកម្មចំនួនប្រមាណ ៦៦ ០០០ ដែលរាយការណ៍ថា បានជះឥទ្ធិពលយ៉ាងខ្លាំង ទៅលើគ្រួសារកសិកម្មក្នុងរយៈពេលយោង។ ទីបីគ្រោះហានិភ័យផ្សេងទៀត ត្រូវបានបញ្ជាក់ឡើងថា មានគ្រោះ ហានិភ័យធ្ងន់ធ្ងរទៅលើគ្រួសារកសិកម្មជាសរុបមានប្រមាណ ៥០ ០០០។




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥




ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

នៅឆ្នាំ២០២៥ គ្រួសារកាន់កាប់កសិកម្មដែលបានទប់ទល់នឹងការរងគ្រោះហានិភ័យមានភាពខុសគ្នាខ្លាំងទៅតាមតំបន់នីមួយៗ។ តំបន់បឹងទន្លេសាបមានចំនួនគ្រួសារខ្ពស់ជាងគេ ទាំងការដែលបានស្តារឡើងវិញទាំងស្រុង និងមិនទាន់បានស្តារឡើងវិញ។ ជាក់ស្តែង មានគ្រួសារចំនួន ៤៩ ០០០ បានរាយការណ៍ថា បានស្តារឡើងវិញទាំងស្រុងពីគ្រោះហានិភ័យ ខណៈដែលគ្រួសារចំនួន ១០៤ ០០០ មិនទាន់អាចស្តារឡើងវិញបានពេញលេញ។ ដូចគ្នានេះដែរ មានគ្រួសារចំនួន ២១ ០០០ បានបញ្ជាក់ថាអាចរៀបចំទប់ទល់នឹងគ្រោះហានិភ័យបានប្រសើរជាងមុននាពេលអនាគត ខណៈដែលគ្រួសារចំនួន ១៣២ ០០០ បានរាយការណ៍ថា នៅតែមិនទាន់បានរៀបចំទប់ទល់នឹងគ្រោះហានិភ័យបែបនេះ។ តំបន់វាលទំនាបមានចំនួនគ្រួសារខ្ពស់លំដាប់ទីពីរនៅគ្រប់ក្រុមទាំងអស់ បន្ទាប់មកគឺតំបន់ខ្ពង់រាបនិងភ្នំ ខណៈដែលតំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារទាបជាងគេ។ ជារួមលទ្ធផលបានបង្ហាញថា នៅគ្រប់តំបន់ទាំងអស់ ចំនួនគ្រួសារដែលមិនទាន់បានស្តារខ្លួនឡើងវិញទាំងស្រុងនិងមិនទាន់បានរៀបចំទប់ទល់នឹងគ្រោះហានិភ័យ មានចំនួនលើសលប់បើប្រៀបធៀបនឹងគ្រួសារដែលបានស្តារឡើងវិញទាំងស្រុង ឬបានរៀបចំទប់ទល់នឹងគ្រោះហានិភ័យ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

នៅតាមតំបន់ទាំងអស់ ការឆ្លើយតបនឹងមធ្យោបាយទប់ទល់នឹងគ្រោះហានិភ័យដែលបានរាយការណ៍ច្រើនជាងគេគឺ (មិនបានធ្វើអ្វីទាំងអស់)។ ការឆ្លើយតបនេះភាគច្រើននៅតំបន់បឹងទន្លេសាប ដែលមានចំនួន ១១៦ ០០០គ្រួសារ បន្ទាប់មកគឺតំបន់វាលទំនាប (៤៩ ០០០គ្រួសារ) តំបន់ខ្ពង់រាបនិងភ្នំ (២៣ ០០០គ្រួសារ) និងតំបន់ឆ្នេរសមុទ្រ (៦ ០០០គ្រួសារ)។ យុទ្ធសាស្ត្រទប់ទល់ផ្សេងទៀតត្រូវបានអនុវត្តដោយគ្រួសារមួយចំនួនគួរឱ្យកត់សម្គាល់។ ការលក់ផលដំណាំនិង/ឬសត្វ គឺជាយុទ្ធសាស្ត្រដែលត្រូវបានប្រើប្រាស់ច្រើនជាងគេលំដាប់ទីពីរ ដែលភាគច្រើនកើតមាននៅតំបន់បឹងទន្លេសាប (១៦ ០០០គ្រួសារ) និងតំបន់វាលទំនាប (៦ ០០០គ្រួសារ)។ ចំណែកឯគ្រួសារមួយចំនួនតូចនៅតំបន់បឹងទន្លេសាប បានរាយការណ៍ថា ពួកគេបានស្វែងរកការងារក្រៅវិស័យកសិកម្ម និងកាត់បន្ថយចំណាយលើការផលិត ដើម្បីឆ្លើយតបនឹងការទប់ទល់គ្រោះហានិភ័យ។



ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៥

តារាងឧបសម្ព័ន្ធ

តារាងទី១. ផ្ទៃដីបានដាំដុះដំណាំ គិតជា ហិកតា (**CAS**:1 **Jul** 2024 - 30 **Jun** 2025)

ការប្រើប្រាស់ក្បាលដី Land use	គ្រួសារកសិកម្ម			សហគ្រាសកសិកម្មខ្នាតធំ/Area (ha)		
	ផ្ទៃដីបានដាំដុះ Area planted (ha)	ផ្ទៃដីបានប្រមូលផល Area harvested (ha)	ផ្ទៃដីបានដាំដុះមិនទាន់ប្រមូលផល Area not harvested * (ha)	ផ្ទៃដីបានដាំដុះ Area planted (ha)	ផ្ទៃដីបានប្រមូលផល Area harvested (ha)	ផ្ទៃដីបានដាំដុះមិនទាន់ប្រមូលផល Area not harvested * (ha)
ដំណាំរយៈពេលខ្លី	៣,៧៣៩,៨៦៤	៣,៧១៧,៣៦៩	១,២៤៣,០៤៤	៤៣,១០៤	៣៥,៦៧១	២៣,៦៨៥
ដំណាំរយៈពេលវែង	៩១៩,៤៨១	៧០៨,៤៤១	-	៣១២,២១៨	២១៩,៩២៦	-
សរុប	៤,៦៥៩,៣៤៥	៤,៤២៥,៨១០	១,២៤៣,០៤៤	៣៥៥,៣២២	២៥៥,៥៩៨	២៣,៦៨៥

*ផ្ទៃដីបានដាំដុះមិនទាន់ប្រមូលផល ព្រោះមិនទាន់ដល់រដូវប្រមូលផល

តារាងទី២. ផ្ទៃដីបានដាំដុះដំណាំស្រូវ គិតជា ហិកតា

ការប្រើប្រាស់ក្បាលដី Land use	គ្រួសារកសិកម្ម			សហគ្រាសកសិកម្មខ្នាតធំ Area (ha)		
	ផ្ទៃដីបានដាំដុះ Area planted (ha)	ផ្ទៃដីបានប្រមូលផល Area harvested (ha)	ផ្ទៃដីបានដាំដុះមិនទាន់ប្រមូលផល Area not harvested * (ha)	ផ្ទៃដីបានដាំដុះ Area planted (ha)	ផ្ទៃដីបានប្រមូលផល Area harvested (ha)	ផ្ទៃដីបានដាំដុះមិនទាន់ប្រមូលផល Area not harvested * (ha)
ស្រូវធម្មតា	២,៥០៨,០៩៥	២,៤៩៥,៧៣០	៧៥១,៤៣០	៧៥០	៧៥០	៧០៧
ស្រូវក្រអូប	៦៥៦,១០៦	៦៥១,៩៩០	២៨២,១២៥	១៧០	១៧០	៣០
ស្រូវដំណើប	៤,១១៦	៤,១១៦	២,៩៥៨	-	-	-
សរុប	៣,១៦៨,៣១៨	៣,១៥១,៨៣៧	១,០៣៦,៥១៥	៩២០	៩២០	៧៣៧

*ផ្ទៃដីបានដាំដុះមិនទាន់ប្រមូលផល ព្រោះមិនទាន់ដល់រដូវប្រមូលផល

តារាងទី៣. ចំនួនបសុសត្វនិងបសុបក្សី បែងចែកតាមគ្រួសារកសិកម្ម និងសហគ្រាសកសិកម្មខ្នាតធំ គិតជាចំនួនក្បាល

បសុសត្វ និងបសុបក្សី	គ្រួសារកសិកម្ម		សហគ្រាសកសិកម្ម		សរុប	
	ចំនួនគ្រួសារដែលបានចិញ្ចឹម	ចំនួនសត្វដែលមាន (ក្បាល)	ចំនួនសហគ្រាសដែលបានចិញ្ចឹម	ចំនួនសត្វដែលមាន (ក្បាល)	ចំនួនគ្រួសារដែលបានចិញ្ចឹម	ចំនួនសត្វដែលមាន (ក្បាល)
គោ	៦៣៨,៧៨០	២,៨៣២,៧០០	១៨	៣៥,០៩៨	៦៣៨,៧៩៨	២,៨៦៧,៧៩៨
ក្របី	៤១,៧៤០	២១១,០០០	-	-	៤១,៧៤០	២១១,០០០
សេះ	៣៣១	-	-	-	-	-
ជ្រូក	១០៣,៩៧០	៩៧១,៣០០	៨៤	៦០៩,១៨១	១០៤,០៥៤	១,៥៨០,៤៨១
ពពែ	១,៤១០	-	-	-	-	-
មាន់	៨៨៦,៩២០	២២,២១០,០០០	៧៥	៣,៦១៤,៣២៥	៨៨៦,៩៩៥	២៥,៨២៤,៣២៥
ទា	១១២,៩០០	១២,៩៤១,៨០០	១២	៦១,៤៥០	១១២,៩១២	១៣,០០៣,២៥០
ក្ងាន	១៣,០៦០	១០៣,០០០	-	-	១៣,០៦០	១០៣,០០០
សរុប	**១,៧៩៩,១១១**	**៣៩,២៦៩,៨០០**	**១៨៩**	**៤,៣២០,០៥៤**	**១,៧៩៧,៥៥៩**	**៤៣,៥៨៩,៨៥៤**

តារាងទី៤: វ៉ារីវប្បកម្ម បែងចែកតាមគ្រួសារកសិកម្ម គិតជាគីឡូក្រាម

ប្រភេទវ៉ារីសត្វ	គ្រួសារកសិកម្ម	
	ចំនួនគ្រួសារដែលបានចិញ្ចឹម	បរិមាណផល (គីឡូក្រាម)
ត្រីទីឡាព្យា	៨៣៣៤.៣១៩	៥៤៤៣០៣.១
ត្រីឆ្ពិន	១០៩៧.០៩៥	១៩៥៩៥៧
ត្រីកាបសាមញ្ញ (ឬ ត្រីកាបស)	-	-
ត្រីកាបប្រាក់	៧៥៩៩.៨៩៧	២០២១២២២
ត្រីកាបឥណ្ឌា (ត្រីរ៉ូហ៊ូ)	២៥.៣៤៤០៣	៣០៤១២.៨៣
ត្រីសាល់តាន់ (ឬ ត្រីត្រសក់)	-	-
ត្រីប្រា	៤៦០៥៨.៣១	១២០៣០០០០
ត្រីកន្ធរ	៤៩៧.០៩០៣	៣៣៣០៥.០៥
ត្រីកាហៃ	៣៦៤.៤៤៣៣	៤៥៥៥.៥៤១
ត្រីឆ្ពោ	៤៦១៣.២៥៨	៤៦២២២៦៨
ត្រីរ៉ស់	៣៧៦៧.០១	១៤៣៤៨៤០
ត្រីកុយ (ឬ ត្រីអណ្តែងកន្ទុយក្រហម)	-	-
ក្រុមត្រីអណ្តែង / ត្រីប្រា	១៥០៣៥.៤៥	១៨៩២៦៦៩

អន្ទង់	-	-
កង្កែប	៣៦៧៥.២២៧	៧៤៦៨៤០.១
បង្កងទឹកសាប	-	-
ត្រីកាស្វៃ (ឬ ត្រីក្រហម)	១៨៨.៧៥២១	៣៧១២៤.៣១
ត្រីតុកកែ	-	-
បង្គាខ្លា ឬ បង្គាស (បង្គាស្រាល)	-	-
ផ្សេងៗ	១៨៧២.៧៥៧	១២២៧៩.៦៣

តារាងទី៥. ផ្ទៃដីបានដាំដុះ និងប្រមូលផល បែងចែកតាមមុខដំណាំសំខាន់ៗ គិតជាហិកតា

ដំណាំ/Crop	គ្រួសារកសិកម្ម		សហគ្រាសកសិកម្ម		សរុប	
	ផ្ទៃដីបានដាំដុះ Area planted (ha)	ផ្ទៃដីបានប្រមូលផល Area harvested (ha)	ផ្ទៃដីបានដាំដុះ Area planted (ha)	ផ្ទៃដីបានប្រមូលផល Area harvested (ha)	ផ្ទៃដីបានដាំដុះ Area planted (ha)	ផ្ទៃដីបានប្រមូលផល Area harvested (ha)
កៅស៊ូ	១៦៤,៣៨០	១០១,៥៤៧	២០៩,១៧៦	១៦៧,១៨០	៣៧៣,៥៥៧	២៦៨,៧២៦
ស្វាយចន្ទី	៥៧៩,៥៥២	៥១០,៧៦៧	២២,៩៦៨	១៥,២០៩	៦០២,៥១៩	៥២៥,៩៧៦
អំពៅ	២,៩០៧	២,៨៦១	២០,៩៨៧	២០,៩៨៧	២៣,៨៩៥	២៣,៨៤៨
ដូងប្រេង	-	-	១៩,២៦៣	១៩,២៤៦	១៩,២៦៣	១៩,២៤៦
ដើមឈើ (យកឈើ) / ឈើហ៊ុប	-	-	៨,៧៦៧	៦,៥២០	៨,៧៦៧	៦,៥២០
ដើមប្រេងខ្យល់	៣	៣	៧,៦២៤	១,២៣១	៧,៦២៧	១,២៣៤
ចេក	១១,៩២០	៦,០៦៦	៧,២៣៦	៥,៩៣៦	១៩,១៥៦	១២,០០២
ពោត (ស/លឿង/ស្វាយ)	៨៥,៩៩៤	៨៥,៨៤៦	៥,០៦១	៥,០៦១	៩១,០៥៤	៩០,៩០៧
ស្វាយ	៥២,១៩៨	៤៨,០៦៧	៤,១៣៥	៣,៣៩១	៥៦,៣៣៣	៥១,៤៥៨
ដំឡូងមី	៤២១,៣១៦	៤១៥,៧៤៤	៣,៥១៣	៣,៥០៣	៤២៤,៨៣០	៤១៩,២៤៧

ដូង	២៥,៦៩៥	១២,៥៤០	៣,៣៥៣	៤០៤	២៩,០៤៨	១២,៩៤៤
សណ្តែកសៀង	៩,១២៤	៩,០៦៧	៣,៣០០	៣,៣០០	១២,៤២៤	១២,៣៦៧
សណ្តែកបាយ	៣,៨៣៩	៣,៨៣៩	១,៥០០	១,៥០០	៥,៣៣៩	៥,៣៣៩
ស្រូវមិនក្រអូប	២,៥០៨,០៩៦	២,៤៩៥,៧៣១	៧៥០	៧៥០	២,៥០៨,៨៤៦	២,៤៩៦,៤៨១
ម្រេច	៦,០២២	៥,០៩០	៥០២	៥០២	៦,៥២៤	៥,៥៩១
ទុរេន	១១,៩៩៨	៦,១១៣	៤១២	៩៥	១២,៤០៩	៦,២០៨
ឫស្សី	២២៤	២២១	២០០	-	៤២៤	២២១
ស្លឹកគ្រៃ	១,៦៩៦	១,៦៩៦	២០០	២០០	១,៨៩៦	១,៨៩៦
កាកាវ	៦៨	៦៨	១៧៧	២៧	២៤៤	៩៤
ស្រូវក្រអូប	៦៥៦,១០៦	៦៥១,៩៩១	១៧០	១៧០	៦៥៦,២៧៧	៦៥២,១៦១
ម្ទេស	៧៩៩	៧៩៥	១០០	១០០	៨៩៩	៨៩៥
ឪឡឹក	៤៦១	៤៦១	១០០	១០០	៥៦១	៥៦១
មៀន	៦,០៦៧	៤,១០៩	៨៥	៨៥	៦,១៥២	៤,១៩៤
ល្មៃ	២៥២	១៥២	៥៨	៤៩	៣១១	២០១
ក្រូចថ្លុង	៣៨៧	២៥៧	២៤	-	៤១១	២៥៧
កាហ្វេ	២០៥	១៣៣	១៨	១៨	២២៣	១៥១

ក្រូច (ឬ ក្រូចពោធិ៏សាត់)	២,៣០៨	១,៥០៩	១៦	១៦	២,៣២៤	១,៥២៥
ខ្នុរ	២,៩៥៩	១,៣១២	១	១	២,៩៥៩	១,៣១២
ផ្លែបឺរ	២៥១	៧២	១០	៤	២៦១	៧៦
សាវម៉ាវ	១,២៤០	៩២៤	១០	៥	១,២៥០	៩២៩
ត្របែក	៣៥៣	២៥៣	៩	៩	៣៦២	២៦២
ទៀប	២,១៩៦	១,២៧៩	១	-	២,១៩៦	១,២៧៩
ម្នាស់	២៣៦	២២៥	១	-	២៣៧	២២៥
ដើមគ	៨	៦	-	-	-	៦
សរុប (Total)	**៤,៥៥៨,៨៦០**	**៤,៣៦៨,៧៤២**	**៣១៩,៧២៧**	**២៥៥,៥៩៩**	**៤,៨៧៨,៥៧៨**	**៤,៦២៤,៣៤០**